ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ១ លេខ ៤

ខែធ្នូ ព. ស. ២៤៩២

ឆ្នាំសិក្សា ១៩៤៩-១៩៥០

ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង

ទំព័រ


ពាក្យប្រែ បារាំង - ខ្មែរ ............................................ ៣

សាលាបាឡីរងវត្តឧណ្ណាលោម ............................................ ៧

ឧត្តមដ្ឋាន ............................................ ១១

មជ្ឈិមដ្ឋានទី ២ នឹងមជ្ឈិមដ្ឋានទី ១ ............................................ ១៣-១៥

វេយ្យាករណ៍ ............................................ ១៨

អាទិកដ្ឋាន ............................................ ១៩

មេសូត្ររត់មាត់ ............................................ ២៨

អាទិកដ្ឋាន - នព្វន្ត ............................................ ៣៣

បរិវច្ឆណដ្ឋាន នព្វន្ត ............................................ ៣៦

បរិវច្ឆណដ្ឋាន រង្វាស់រង្វាល់ ............................................ ៤១

កុមារដ្ឋាន-នព្វន្ត នឹងកុមារដ្ឋានរង្វាស់រង្វាល់ ............................................ ៤៤-៤៩

លោកនិតិ - សម្រាប់គ្រប់ថ្នាក់ ............................................ ៥២

សេចក្ដីអធិប្បាយរដ្ឋធម្មនុញ្ញ ............................................ ៥៧

## MOTS A TRADUIRE (suite)

Bibliothèquaire . . . . . . . . : បណ្ណារក្ស (ឬបណ្ណានុរក្ស

Salle d'attente . . . . . . . . :

Céramique . . . . . . . . . . : កុលាលភាជន៍

Garden party . . . . . . . . . : ឧទ្យានសមោសរ

Symbole . . . . . . . . . . . : និមិត្តរូប

Emblème. . . . . . . . . . . . : បដិមរូប

Renvois . . . . . . . . . . . . : នយលក្ខណៈ

Nature (du sel) . . . . . . . . : ភាព (អំបិល)

Destination . . . . . . . . . . : ទីទទួល

Etapes . . . . . . . . . . . . : ដំណាក់

Laissez-passer . . . . . . . : លិខិតបើកផ្លូវ

Quantité . . . . . . . . . . . : បរិមាណ

Délai de route . . . . . . . . : រយៈពេលដើរផ្លូវ

Moyen de transport . . . . . . : មធ្យោបាយដឹកនាំ

Stock . . . . . . . . . . . . . : ស្តុក

Police Nationale . . . . . . . : ក្រុមព្រះនគរបាល

Secrétariat (personnel) . . . : លេខាធិការដ្ឋាន (បុគ្គលិក)

Section de l'identité Judiciaire . : ផ្នែកអត្តសញ្ញាណតុលាការ

Commissariat du port . . . . : ទីស្ដីការកុម្មិស្សែរកំពង់

Police spéciale . . . . . . . . : ប៉ូលិសពិសេស

Police judiciaire . . . . . . . : ប៉ូលិសតុលាការ

Police administrative . . . . . : ប៉ូលិសរដ្ឋបាល

Service financier . . . . . . . : ក្រុមហិរញ្ញវត្ថុ

Bureau fiscal . . . . . . . . . : ប៉ុយ៉ូពន្ធដារ

Service liquidateur . . . . . . : ក្រុមជំរះបញ្ជី

Bureau des contributions des asiatiques étrangers . . . . . . . : ប៉ុយ៉ូពន្ធជំនួយនៃជនអាស៊ីបរទេស

| | |
|---|---|
| Dîner . . . . . . . . . . . : | ការបរិភោគល្ងាច; ការលៀងអាហារល្ងាច |
| Déjeuner . . . . . . . . . . : | ការបរិភោគថ្ងៃ; ការលៀងអាហារថ្ងៃ |
| Cocktail . . . . . . . . . : | ការលៀងសុរា |
| Lunch . . . . . . . . . . : | ការលៀងភេសជ្ជៈ |
| Soirée de gala . . . . . . . : | រាត្រីសមោសរ |
| Théâtre nouveau . . . . . . : | ល្ខោនសម័យថ្មី |
| Goûter . . . . . . . . . . : | ការស្រស់ស្រូបល្ងាច |
| Petit déjeuner . . . . . . : | ការស្រស់ស្រូបព្រឹក |
| Music hall . . . . . . . . : | សាលតន្ត្រី |
| Réserve . . . . . . . . . . : | ទីបំរុង |
| Réserve domaniale . . . . . : | ទីបំរុងទ្រព្យរាជការ |
| Réserve routière . . . . . . : | ទីបំរុងថ្នល់ |
| Réserve fluviale . . . . . . : | ទីបំរុងទន្លេ |
| Réserve maritime . . . . . . : | ទីបំរុងសមុទ្រ |
| Chef de la division cadastrale . : | មេផ្នែកសុរិយោដី |
| Chef du Bureau Foncier . . . : | នាយប៊ុយរ៉ូភូមិបាល |
| Agent de Bureau . . . . . . : | ភ្នាក់ងារប៊ុយរ៉ូ |
| Bureau Foncier . . . . . . : | ប៊ុយរ៉ូភូមិបាល |
| Ingénieur . . . . . . . . : | វិស្វករ |
| Agent technique . . . . . . : | វិស្វកររង |
| Géomètre conservateur . . . : | អ្នករេខាគណិត - អភិរក្ស |
| Géomètre-civil . . . . . . . : | អ្នករេខាគណិតស៊ីវិល |
| Arpenteur-Dessinateur . . . . : | រដ្ឋករ - ចិត្រករ |
| Opérateur . . . . . . . . . : | ការី, ឥ. f. ការិណី |
| Inspecteur . . . . . . . . . : | អធិការ |
| Contrôleur . . . . . . . . . : | អ្នកត្រួត |
| Conservateur . . . . . . . : | អភិរក្ស |

| | |
|---|---|
| Bureau du Cadastre Municipal de la voirie de Phnom-Penh . . : | ប៊ុយរ៉ូសុរិយោដីភជការក្រុងភ្នំពេញ |
| Chef du Bureau conservateur . : | នាយប៊ុយរ៉ូអភិរក្ស |
| Conservation cadastrale . . : | មន្ទីរអភិរក្សសុរិយោដី |
| Conservation du domaine . . : | ការអភិរក្សនៃទ្រព្យភជការ |
| Domaine privé . . . . . . : | ទ្រព្យភជការអសាធារណៈ |
| Domaine public . . . . . : | ទ្រព្យភជការសាធារណៈ |
| Subdivision des travaux neufs . : | ផ្នែករងនៃនវកម្ម |
| Topographie . . . . . . . . : | ហ៊ិនលេខា |
| Topométrie . . . . . . . . . : | ហ៊ិនគណិត |
| Géométrie . . . . . . . . . : | រេខាគណិត |
| Géodésie . . . . . . . . : | ប្រឹថពីវិភាគ |
| Travaux de géodésie . . . : | ការប្រឹថពីវិភាគ |
| Travaux de restitution . . . . : | ការវាស់តម្រូវ (ពាក្យសុរិយោដី) |
| Travaux de cadastrage . . . . : | ការវាស់ - តែងបញ្ជីដី |
| Lever et immatriculer des terres : | វាស់ចុះបញ្ជីដី |
| Inspection . . . . . . . . . : | អធិការដ្ឋាន |
| Concession . . . . . . . . . : | សម្បទាន |
| Plan d'aménagement . . . . . : | ផែនទីរៀបចំដី |
| Plan déalignement . . . . . : | ផែនទីរៀបផ្លូវដី |
| Plan de lotissement . . . . . : | ផែនទីរៀបខ្ទង់ដី |
| Plan parcellaire . . . . . . . : | ផែនទីក្បាលដី |
| Parcelle . . . . . . . . . . : | ក្បាលដី |
| Laboratoire de photo-restitution : | ទីពិសោធកែតម្រូវរូបថត |
| Commission administrative . . : | គណៈកម្មការរដ្ឋបាល |
| Commission de bornage . . . : | គណៈកម្មការព្រំដី |
| Plan topographique . . . . . : | ផែនទីហ៊ិនលេខា |
| Lever par rayonnement . . . : | វាស់ដោយវិធីរស្មី |

| | |
|---|---|
| Lever par relèvement . . . . : | វាស់ដោយវិធីសាជាន |
| Lever par cheminement . . . : | វាស់ដោយវិធីបន្ត |
| Lever par intersection . . . . : | វាស់ដោយវិធីបន្ទាត់កាត់គ្នា |
| **O**pérations géodésiques . . . : | ការប្រឹថពីវិភាគ |
| Triangulations générales des 1er 2e, 3e ordres, secondaires ou fondamentales se rapportent aux levés par topographie aérienne: | ត្រីកោណវិធីទូទៅលំដាប់ទី ១, ទី២, ទី៣, បន្ទាប់ ឬជាមូលដ្ឋាន ដែលទាក់ទងនឹងការវាស់ដោយហ៊ានលេខាពីលើអាកាស ។ |
| Triangulations subsidiaires cadastrales de restitution photo aérienne de 4e ordre et au dessous: | ត្រីកោណវិធបន្ទាប់បន្សំ, សុរិយោគីនៃការវាស់តម្រូវកែរូបថតពីលើអាកាសនៃលំដាប់ទី ៤ និងលំដាប់ថយមក ។ |
| Statistique . . . . . . . . . : | ស្ថិតិ ( ស្ថិ - តិ = បញ្ជីប្រាប់ចំនួន ) |
| Opération . . . . . . . . . : | ប្រតិបត្តិការ ( ប្រ: - តិ - បាត់ - តិ - កា ) |

# សាលាបាឡីរងវត្តឧណ្ណាលោម

ថ្ងៃ ២៣ សីហា ១៩៤៨ (ព.ស. ២៤៩១)

## ទុតិយាវិភត្តិ (ត)

ខ) "កាន់" ហៅថា សម្បាបុណិយកម្ម ឧ. ត្រូវបង្គាប់ឲ្យឈ្មោះ "ក" ចូលមកកាន់មន្ទីរស្ដីការក្រសួងយុត្តិធម៌នៅថ្ងៃ ២០ សីហា ១៩៤៨ វេលាម៉ោង ១៦ ។ បក្សីទាំងឡាយតែងតែហើរវិលមកកាន់ទ្រនំវិញរាល់ល្ងាច ។

គ) "ញុំាង" ហៅថា ការិតកម្ម. ឧ. ព្រះអាទិត្យញុំាងលោកឲ្យភ្លឺ = (ព្រះអាទិត្យបំភ្លឺលោក) ។ គ្រូញុំាងសិស្សឲ្យរៀន = (គ្រូបង្រៀនសិស្ស) ។ អំពើអាក្រក់តែងតែញុំាងអ្នកធ្វើឲ្យដល់នូវសេចក្ដីវិនាស ។

ឃ) "អស់" ហៅថា អច្ចន្តសំយោគ, ឧ. ខ្ញុំទៅនៅព្យាបាលរោគឯមន្ទីរពេទ្យព្រះកេតុមាលាអស់មួយខែគត់ ។ ខ្ញុំធ្លាប់ទៅនៅឯព្រៃនគរអស់កាលយូរ ។

ង) "នឹង" ឬ "ចំពោះ" ហៅថា អភិបិតកម្ម, ឧ. គេបាននិយាយពាក្យនេះនឹងខ្ញុំ, ឬ-ចំពោះខ្ញុំ ។

## តតិយា

៣ – តតិយាវិភត្តិ ប្រើពាក្យជាអាយតនិបាត ដូចខាងក្រោមនេះ

ក) "ដោយ" ហៅថា ករណៈ, ឧ. សត្វលោកសុទ្ធតែធ្វើអំពើទាំងពួងដោយគ្រឿងគឺកាយ, វាចា, ចិត្ត ។ ព្រានប្រមាញ់បាញ់សត្វដោយកាំភ្លើង ។

ខ) "ដោយខ្លួន; ដោយសារ, ដោយសារតែ; តាម" ហៅថា វិសេសនៈ ឬ វិសេសនត្ថៈ, ឧ. អ្នកប្រាជ្ញរៀនដោយខ្លួនគិតធម៌ ។ មនុស្សខ្វិនទៅមកបាន ដោយសារគេគិល ។ ពួកបព្វជិតរស់នៅបានដោយសារតែទានរបស់ទាយក ។ អ្នកទាំងឡាយចូរដើរតាមខ្ញុំៗ គេចេញពីក្នុងផ្ទះតាមទ្វារ ។

ថ្ងៃពុធ ២៥ សីហា ១៩៤៨ ព.ស. ២៤៩១

គ) "គឺ, ដែល" ហៅថា អនភិហិតកត្តា, ឧ. ការនេះគឺខ្ញុំធ្វើ ។ ផ្ទះនេះគឺខ្ញុំចេញប្រាក់ឲ្យសង់ ។ ផ្លូវនេះឬដែលរាជការហាមមិនឲ្យបររទេះគោ ។

ឃ) "ហេតុ, ហេតុតែ, ព្រោះ, ព្រោះតែ" ហៅថា ហេតុឬហេតុត្ថៈ, ឧ. បានជាខ្ញុំចេះតែទ្រាំអត់មិនស្តីថាអ្វី ហេតុមកពីមិនចង់ឲ្យមានរឿង ។ ហេតុតែខ្លាចល្ងង់ទៅ បានជាខ្ញុំមកពឹងរកយើងឲ្យជួយណែនាំ ។ សត្វលោកមានចិត្តប្រែប្រួលព្រោះលោកធម៌គ្របសង្កត់ ។ បានជាគាត់ចេះតែត្រាញនៅក្នុងទីនោះ ព្រោះតែលាភៈនិងសក្ការៈ ។

ង) "មាន" ហៅថា ឥត្ថម្ភូត, ឧ. កុមារនោះមានម្ដាយមិនបង្កើតជាអ្នកទំនុកបំរុង ក៏ខំប្រឹងរៀនសូត្រត្រាតែបានសំរេចវិជ្ជាថ្នាក់ខ្ពស់ ។

ច) "ជាមួយនឹង" ហៅថា សហត្ថៈ, ឧ. នាងកញ្ញាទៅផ្សារជាមួយនឹងម្ដាយ ។ លោកនាយករដ្ឋមន្ត្រីប្រឹក្សាការជាមួយនឹងឧបនាយករបស់លោក ។

---

## ពាក្យដែលត្រូវប្រើជាមួយនឹង "ដោយ"

១ – គប់ដោយសុវត្ថិភាព ។ ល ។

២ – ប្រកបដោយសន្តិសុខ ។ ប្រកបដោយសីលធម៌ ។ ប្រកបដោយវឌ្ឍនធម៌ ។

៣ – បរិបូណ៌ដោយភោគទ្រព្យ ។ ល ។

៤ – សម្បូណ៌ដោយភោជនាហារ ។ ល ។

៥ – វិចិត្រដោយក្បូរក្បាច់រចនា ។ ល ។

៦ – រំលេចដោយពណ៌ផ្សេង ៗ ។ ល ។

ពាក្យ "ដោយ" ប្រើជាជំនួសកិរិយាវិសេសនៈ (Adverbe) ផងក៏មានខ្លះ, ឧ. ដោយរហ័ស: ដោយប្រញាប់; ដោយច្រើន ។ ល ។ (មានសេចក្ដីស្មើគ្នានឹងពាក្យ "យ៉ាង") ។

ថ្ងៃ ៣០ សីហា ១៩៤៨ (ព.ស. ២៤៩១)

## ចតុត្ថី

៤– ចតុត្ថី វិភត្តិ ប្រែពាក្យជាអាយតនិបាតដូចខាងក្រោមនេះ (ហៅថា សម្បទាន: ដូចគ្នាទាំងអស់) ។

ក) "ដល់" ឧ. មនុស្សអ្នកបរិបូណ៌ដោយករុណា តែងបរិច្ចាគទាន ដល់សមពុំសូវដែលខាន ។ គ្រូជាអ្នកឲ្យចំណេះវិជ្ជាដល់សិស្ស ។

សំរាប់ឥស្សរៈជនថ្នាក់ខ្ពស់ កុំប្រែពាក្យដល់ ត្រូវប្រែពាក្យ "ចំពោះ" ជាដំរូប, ឧ. ក្នុងទីបញ្ចប់នៃសុន្ទរកថានោះ អ្នកដើមមុណ្ឌប្រកាសសេចក្តីយ៉ាងក្បោះក្បាយថ្វាយព្រះពជកុសលចំពោះព្រះករុណាជាម្ចាស់ជីវិតលើត្បូង··· ។

ខ) "ដើម្បី, បំរុង" ឧ. អ្នករៀនខំប្រឹងសិក្សាដើម្បីឲ្យខ្លួនមានចំណេះ រដ្ឋាភិបាលចាត់ការឲ្យមានសេនាទាហានបំរុងការពារប្រទេសឲ្យមានសន្តិភាព ។

គ) "ចំពោះ, ទិន" (មានសេចក្តីថា "ឆ្ពោះទៅរក") ឧ. អ្នកណាប្រទូស្តចំពោះបុគ្គលដែលឥតកំហុស, អ្នកនោះប្រិនតែមានសេចក្តីវិនាសឃើញស្តែងទាន់ភ្នែក ។ ឯងកុំខឹងនឹងអញ, បានជាអញស្តីថាឲ្យឯង ព្រោះចង់ឲ្យឯងល្អ ។

## បញ្ចមី

៥– បញ្ចមី វិភត្តិ ប្រែពាក្យជាអាយតនិបាត, សំរាប់ភាសាសំស្រ្កិត

និទស្សនៈ មានវិធីនិងដំណើរផ្សេងគ្នាពីភាសាខ្មែរខ្លះ, សំគាល់ភាសាខ្មែរដូចខាងក្រោមនេះ :

ក) "អំពី, ពី" ហៅថា **អញ្ញទាន**, ឧ. ភ័យអំពីមរណៈ ។ អ្នកអញ្ជើញមកពីណា ទៅណា ហ្នឹង? — ខ្ញុំមកពីបការទៅផ្ទះ ។

ខ) "ចាក" ហៅថា **អញ្ញទាន** ដែរ, ឧ. បុគ្គលត្រូវវៀរចាកទុច្ចរិត ជីតាខ្ញុំចេញចាកលោកនេះទៅកាន់បរលោក កន្លងជាង ២០ ឆ្នាំហើយ ។ ព្រះសព្វញ្ញុពុទ្ធបានជាទ្រង់ព្រះនាមថា "អរហំ" ព្រោះព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង ។

---

ឧត្តមដ្ឋាន

## រៀនមើល-សរសេរតាមសូត្រ

## ផ្លូវឌូដារដឺឡាគ្រេ

ផ្លូវនេះមាននាមដូច្នេះ រំឭកដល់លោកមេទ័ពជាតិបារាំងសែសម្នាក់ ដែលបានចូលមកជាប្រថមយកស្រុកកម្ពុជា ។ សម្ពន្ធមិត្រនឹងស្រុកបារាំងសែស លោកមេទ័ពនេះឯងនៅគ្រប់គ្រងកិច្ចការ ប្រតិបត្តិកិច្ចទៀបជិតព្រះអង្គព្រះបាទនរោត្តម តាំងពីគ្រិស្ដសករាជ ១៨៦៣ ។ ផ្លូវឌូដារដឺឡាគ្រេ ជាផ្លូវធំទូលាយហើយវែងឆ្ងាយលើសផ្លូវដទៃ ទីស្ថិតនៃផ្លូវនៅចំកណ្ដាលទីក្រុង សន្ធឹង

ពីភ្នំពេញទៅដាច់ទីផ្លូវទៅក្រៅនគរ ៗ ពីឆ្នាំ ១៩៣៨ លំអផ្លូវនេះល្អ ស្រួលដីមានផ្ទៃរាបស្មើ រាគទទឹងឲ្យធំទូលាយកំពស់សំដងក្រៅ ដែលអាច បំបាត់បង់ កក់ជ្រាំទូវផង់ធូលី ៗ នៅទទឹងផ្លូវមានផ្លូវដងគោម ដំហើយទូវ ចុងវែកជាប់ ខ្សែល្អស្រគើងកក់ក្នុងដីដើម្បីមិនឲ្យទទេសទទាស់ ៗ តាម បណ្តោយផ្លូវយើងឃើញគោម ដូចកម្រិនជាតគ្នាហៅជាខ្សែបី ដែលគ្រឿងពាន ជះទៀងទៅអាកាស ពន្លឺភាសចាំងមណ្ឌលផ្លូវ ៗ តាមក្បែរសងខាងផ្លូវ មានទេសន្សាគយគន់មើលផ្ទះធំ ៗ ល្អ ៗ ពីក្រោយផ្លូវដើមឈើ ឲ្យមួបសំកាប់ លំអផ្លូវ ៗ សត្វសំទៀងនិងសត្វផ្សេងៗដែលជាប់ មនុស្សគ្រាប់ទៅមកកើម ខ្វះដើរ ខ្វះជិះយានជំនួនសម្ញៀកបំពាក់ហ៊ីហារ គួរនាំដូចភ្ញាសបុណ្យផ្លែន បកបក្កុងផ្លូវនេះ មានសណ្តាប់ គឺគ្រាប់ទៅនិយមកមិនប្រទូកគ្នា ព្រោះអ្នក បរការសំភ្លាកលំខ្លួន ៗ ត្រង់ទៀតខ្សែងកែងមានភ្នាក់ងាររយាមចាំហាមឃាត់ ឲ្យប្រតិបត្តិ តាមបញ្ញតិផ្លូវ ៗ

ការលំអផ្លូវនៅគ្រប់ប្រទេសដូចជាផ្លូវខ្លួនជាដំឡូងក្រែ នៅស្រុកយើងនេះ ជាការមួយប្រសើរ ព្រោះនាំមហាជនឲ្យមានគតិទៅការសេចក្តីលូតរ៉ើងក្នុង សម័យលោក គឺជាជម្រុនានទូនានដល់អ្នកទាំងពួងឲ្យធ្វើតាមជគបង្គាប់ឲ្យមាន រម្ងៀសទិនទ្រណាបុរីនិងខ្លួនឯង គឺនរណាទេកាន់ទំលុសំងកែងខ្លួនល្អ យាន ជំនិះល្អទើបបរលើផ្លូវល្អ គេហដ្ឋានល្អទើបគួរនៅផ្ទះល្អ ជំបូនានយ៉ាងនេះហៅ ជំបូនានដោយវត្ត ៗ

អានពាក្យ.— សម្ពន្ធ ឲ្យមើលថា= សំពាន់មិត្រ ។— ទស្សនា= មើលថា= ទស់-សៈ-ណា ។

ពន្យល់ពាក្យ= សម្ពន្ធមិត្រ= ចងមិត្រមេត្រី ។— ប្រតិត្តភាត់ ឬប្រតិកត្តភាត់ សចក្ដីទំនុកបំរុង ។

បរាបរ= ទៅនិងមក ឬទៅមក ។— កាន់ស្ដាំ = ដើរខាងស្ដាំដៃនៃខ្លួន ។— ត្រែទៀងកែង-ផ្លូវបែក ។

ពាក្យសួរ= ហេតុអ្វីឈ្មោះផ្លូវផ្លានៃទីក្រុងសឹងជាឈ្មោះមនុស្ស ។— មនុស្សទាំងនោះជាអ្វី ។— ការលំអផ្លូវមានប្រយោជន៍ដូចម្ដេច ។— នឹងដើរតាមផ្លូវធំៗ គេប្រព្រឹត្តដូចម្ដេច នឹងឆ្លងកាត់ថ្នល់ត្រូវធ្វើដូចម្ដេច ។— វណ្ណយុត្តិអ្វីខ្លះដែលប្រើក្នុងបទនេះ ។

---

## មជ្ឈដ្ឋានទី ២

# លើព្រែកគន្ធា ឬព្រែកក្រអូប

គ្មានពាក្យសំដីឯណាមួយថ្លែងបានឡើយ ការស្ងប់ស្ងាត់នៃល្ងាចនោះ ការសុខវេទនា, ការក្រេមនៃសត្វទន្ទ្រំទាំងឡាយ ៗ មិនយូរប៉ុន្មានព្រះអាទិត្យមករឡាច ចុះដុតទៅក្រោមជើងមេឃ ខ្យល់រំភើយលេចឡើងក្លាម ស្អិកឈើក៏រើតបន្តិចសត្វកកាយសប្បាយ ៗ សភាពនោះមានឡើងយូរប្រមាណ បីបួនមីនុត កិរិយាស្ងប់ស្ងាត់លេចឡើងជាថ្មី ៗ យប់ស្រឡប់ះមេឃធ្លាក់ ចុះលើផែនដី នោះកន្ទបខ្នោះមាត់ប៉ាន់ទៅនៃទន្លេ ខ្សែទឹកនៅមានពន្លឺព្រាក

បន្តិច ៗ ព្រោះទៀនដូចកាំជ្រួចក្នុងរលកទឹក ហ្វូងអង្រិលអណ្តែតតាំងឡាយ ហើយ ព្រានព្រាតភ្លៀលភ្ញាក់ប៉ប្រាសទឹក រីឯស្រមោលអ្នកចែវទូកលេចធំ ជ្រះឆាងចាប់ទៅទេយ វែលភ្លេកវែង ៗ ដំហានចែវមួយ ៗ គួរនាងដូចដំណើរ យោលនៃប៉ោល ៗ ដំហានចែវម្នាះទៅមុខ ៗ ធំ ៗ បន្សំទឹកសន្ទុះស្រួសសៀន ចំរៀង ដូនក្រោមក្រអៅ ដូនត្រលប់លង់លន្ទោចស្រណោះ ៗ

១– នៅលើព្រែកគគ្នា គេមានចិត្តដូចម្ដេចក្នុងវេលាល្ងាចនោះ ។
២– ព្រែកគគ្នាមានអត្ថជាដូចម្ដេច ។
៣– ហេតុអ្វីបានជាគេថាស្ទឹកឈើសប្បាយ ។
៤– ហេតុអ្វីគេថាព្រះអាទិត្យមេកំទេច ។
៥– ហេតុអ្វីស្រមោលអ្នកចែវទូកលេចឡើងធំធ្រិងោ ។
៦– ន័យជាដូចម្ដេច = សង្វាក់ ។

## ទ្វារពពក

ទ្វារនោះមាននាមត្រូវប្រាកដ ព្រោះនៅទីនោះមានស័ត្វចុះលុបស៊ើរៃត ជានិច្ចជាកាល ៗ គេស្មានថាពពកនៃដំបន់នោះ រសាត់មកតាំងទីទំនៅក្នុង ហើយចេញក្នុងប្រកបនេះស្អៀតនឹងទ្វារ ៗ ខ្ញុំបានធ្លងកាត់ទ្វារនោះច្រើនដងណាស់ ខ្ញុំបានប្រទះពល់ដងតាំងពីចំហ៊ាយ ចំហាយសក្រាសរុំដិតទ្វារ ៗ នេះនៃទ្វារ នោះហើយឃើញដល់ ៗ ផ្លូវដែលទៅតាមទ្វារ សឹងកំដងារប៉ាំងដោយបន្ទាយ យូនមាំស្អិតត្រជិនតប្បស្ទើចចីកន្ទួនសង់ ៗ បន្ទាយនោះសឹងលុបបាត់ក្នុង ស័ត្វដូចឃើនផែរ ប៉ុន្តែវេរីនមកទីនេះស៊ើរែតពុំទាន់ឃល់ឃើន ពពកដែលរុំដុំ

វិញ ។ យើងចាកចេញដោយហោះសំរោក រង្ហើរឡើង រហូតបាត់ទៅដោយខ្យល់ផាត់ចេញ ៗ យើងក៏នៅក្នុងកំឡុងអាកាសស្អាត ថ្លា ហាក់កណ្ដាលព្រះអាទិត្យ ហើយអ្វី ៗ លេចឡើងច្បាស់ស្រឡះឯមុខនិងឯក្រោមយើង ៗ ក៏មើលទៅឃើញឆកតូក៉ន សេចក្ដីរីករាយរបស់យើងកើតឡើងដោយហេតុនោះ

---

១– ក្នុងរឿងនេះគេនិយាយពីអ្វី ។

២– ពាក្យទាំងនេះមានន័យដូចម្ដេច = រសាត់ - ទញ់ - ស្ពឹង ។

៣– ធម្មជាតិអ្វីដែលគេហៅពពក ។

៤– តូក៉នជាស្រុកដូចម្ដេច? នៅឯណា?

៥– អ្វីហៅឆក? ឆកធំហៅអ្វី? ទ្វារភ្នំជាអ្វី? ។

---

មជ្ឈដ្ឋានទី ១

# ភូមិទាំងឡាយនៃយួន

ភូមិទាំងឡាយ ច្រើនបំផុតនៃយួនជាភូមិកសិកម្ម ដែលកសិករជនធ្វើការឯស្រែចំការវេលាថ្ងៃ ៗ វេលាយប់ត្រឡប់ទៅផ្ទះវិញដេកក្រើមទៅផង ៗ មានភូមិអណ្ដែតរបស់អ្នកនេសាទ សង់ជាផ្ទះតែក្បែរមាត់ទន្លេធំ ៗ នៅកយគ្នាសព្វអន្លើ ៗ គេមានចិត្តចង់តែមើលទៅនេសាទជនផ្លាស់ប្ដូរទីកន្លែង គេឃើញនាំទៅជាមួយផងនៅលើក្បូន នេសាទោបករណ៍និងផ្ទះ និងខ្ទមប្រយោជ ភូមិខ្លះទៀតជាភូមិសិប្បកម្ម ដែលសិប្បការជនទាំងឡាយរក្សាសណ្ដាប់ច្រើនយ៉ាងនាំ

មកហើយ ការប្រកបកសិកម្មដាំស្រូវ ធ្វើស្រែចំការ ធ្វើដាំដំណាំ ។ល។ ត្រកូលទាំងនោះធ្វើរបររកស៊ីដូចសង្គមជនគឺធ្វើដោយពួក ទាំងវិធីធ្វើរបរក៏ធ្វើមិនឲ្យល្អៀងពីទំលាប់សណ្តាប់ធ្នាប់ណាឡើយ ។ ប៉ុន្តែទោះជាក្រុមកសិកម្មក្តី ជាក្រុមសិប្បកម្មក្តី ក្រុមទាំងនោះមានភាពប្រហែល ៗគ្នា ។

---

ពាក្យពន្យល់.— កសិកម្ម = អានថា= កៈសិ-កាំ ការធ្វើរបរដាំដំណាំ ។— កសិករ = អ្នកធ្វើរបរដាំដំណាំ ។— នេសាទ = ព្រានចាប់សត្វក្នុងទឹក ។— នេសាទោបករណ៍ ប្រដាប់ប្រើប្រាស់ក្នុងការនេសាទ ។— សិប្បកម្ម = អានថា = សិប-បៈ កាំ— ការធ្វើរបរខាងវិជ្ជាចំណេះ, ធ្វើផាង, ដេរ, តូរធ្លាក់. . . ។— សិប្បករ= អ្នកដែលធ្វើសិប្បកម្ម ។—សង្គម= អាន= ស័ង-គំ = ពួលគ្នា ក្រុមហ៊ុន ។

ពាក្យសួរ.— គេសំគាល់ឃើញដូចម្តេចភារៈនៃភូមិទាំងឡាយនៃយួន ។— ភូមិធ្វើរបរអ្វីខ្លះ ។— ហេតុដូចម្តេចបានជាគេថា របររកស៊ីនៃយួនដូចជាសង្គមជន ។— អ្នកស្គាល់សិប្បកម្មអ្វីខ្លះ ។

---

## អ្នកស្រែធ្មប់

ក្នុងជំបន់ស្រុកលើ ១ មានដីមានដីជាតិស្មើនិស្សូប ឲ្យផលដំណាំមួយឆ្នាំៗ តែបន្តិចបន្តួច ។ អ្នកជនៃទម្នាក់បានទិញដីឥតផលនោះ ក៏តាំងទីលំនៅៗ ជាមួយប្រពន្ធនិងកូនបួននាក់ ។ ដោយសេចក្តីអាសាអាសាញ់នៃគ្រួសារ ផ្ទះតូចល្មមតែមាំទាំសង់កើតឡើងភ្លាម ហើយដីតាស់កនប្រែត្រឡប់ ទីនាំជាសួន

ហាក់បីចំរើនផលល្អ ស្រូវផ្លែមានគួរធំៗជាងស្រូវនៃស្រែដិតខាង ។ អ្នកស្រុកក្រេង្គៀសប្រែណាននឹងស្រូវល្អ នឹងសេចក្តីអាជីវប្រព្រឹត្តនៃគ្រួសារ ដែលគេពុំដែលឃើញនិយាយលេងសើចជាមួយនរណា នឹងបបួលទៅកន្ទអំពើធោឡោវនៃផលលោះប្រែកែក ក៏ប្រាប់ជនដទៃនោះជាមនុស្សសិល្ប៍ ។ បុរសនោះក៏ត្រូវកំណោះចំពោះមុខមន្ត្រីកាត់ក្តី បាននាំប្រពន្ធនឹងកូនដ៏មានស្វាហាប់ជាអ្នកសុខជា នឹងក្របីមាំៗមួយនឹម ក្របីមួយអស់រទេះបន្ទុកដ៏មានសើផ្ទុកៗ ដោយចំណាំទីថ្វេចេញពីជាលសិតលាន ពីឆ្នោតរោងសរលេងពីកណ្ដៀវ ពីចប ពីប៉ែលនឹងគប់ៗ បុរសដកបទៅក្រមថា សូមទានលោកពិ-តារណាចុះ របស់ទាំងនេះជាវិជ្ជាសិល្ប៍របស់ខ្ញុំប្រើប្រាស់ ។ ខ្ញុំពុំអាចមន្ទាញបានទៀយ សេចក្តីទៀយហាក់នៃគ្រួសារដែលខំធ្វើការ នូវសេចក្ដីល្អិតល្អន់ក្នុងវង្សត្រកូលដែលបង្កើតឡើងឲ្យស្រឡាញ់សេចក្ដីល្អនឹងគោរពច្បាប់ ។ ទៅក្រមក៏បង្កេចពាក្យចោទ ហើយខ្ទានអ្នកទាំងពួងឲ្យយកដំបេតាមបុរសនោះវិញ ។

---

ពាក្យពន្យល់ .— ធ្មប់=វិជ្ជាមន្តគាថាអាចធ្វើឲ្យគេវិនាសបាន ។—អាសាអាសាញ់ធ្វើការមិនខ្ជិលច្រអូស ។ សិល្ប៍= អាគម=សិល = វិជ្ជាមន្តគាថាអាចធ្វើឲ្យកើតហេតុអស្ចារ្យ

ពាក្យចោទ .— ដីដែលគេនិយាយជាដីដូចម្តេច ។ ព្រោះអ្វីដីនោះទៅជាឲ្យផលល្អ បុរសនោះប្រព្រឹត្តយ៉ាងដូចម្តេចបានជាគេប្រាប់ថាធ្មប់ ។ សេចក្តីចោទជាត្រឹមត្រូវឬដូចម្តេច ។

## វេយ្យាករណ៍

# វិធីប្រើវណ្ណយុត្តិ (ត)

ល្បះ (។) សំរាប់ធ្វើពាក្យជាសង្កាត់ ដើម្បីញែកសេចក្ដីឲ្យច្បាស់លាស់ ។ កាកបាទ (+) ប្រើលើពាក្យ នុ៎ះ, ហ្ន៎ះ ។– អស្តា (៨) ប្រើលើនិបាតសព្ទ ក និង ជ និងនិបាតសព្ទខ្វះ ដូចពាក្យ នុ៎ះ ហ្ន៎ ឬ ន៎, មើលន៎ឬហ្ន៎, ឱហ្ន៎ឬន៎ ។– មូសិកទន្ត (") និងត្រីសព្ទ (-) ប្ដូរសព្ទអក្សរទ្វិសព្ទនិងត្រៃសព្ទឲ្យទៅជាអឃោសៈ ឬឃោសៈ ។–គោមូត្រឬបរិយោសាន (៚) ជាសញ្ញាសម្រាប់ប្រើនូវចុងបញ្ចប់សេចក្ដី ។– ពិន្ទុ (៙) សញ្ញាសម្រាប់ចុះខាងដើមផ្ដើមសេចក្ដី ។– វ៉ាត់ ឬ គាប ({) សំរាប់គាបពាក្យ ។– បេ ឬ លៈ (។ល។) ប្រើជាសំគាល់នូវពាក្យដែលនឹងពោលតទៅទៀត ។– វង្គុសញ្ញា (–) ជាគំនូសយោង ។– ពងត្រីឬបុណ្ណសញ្ញា (.....) ជាចន្លោះសម្រាប់ពាក្យដែលត្រូវយកមកបំពេញ ។

## ពីអក្សរព្យញ្ជនៈផ្លាស់ប្ដូររូប

*សុំមើលវេយ្យាករណ៍មេរៀនលេខ ៧ ទំព័រ ៧*

អាទិតក្ខាន

# អាទិត្យទី ១

## បង្រៀនពាក្យ-ហាត់ភាសា

### អំពីទីក្រុង

ពាក្យ.— នាម.— វាំង ប្រាសាទ វត្ត វិហារ ផ្ទះថ្ម រោងល្ខោន សាលា មន្ទីរពេជការ រោងម៉ាស៊ីន (រោងចក្រ) ឃ្លាំងជំនួញ ឃ្លាំងប្រាក់ ផ្សារ ផ្លូវថ្នល់ សួនច្បារ ម៉ាស៊ីនទឹក បង្គៀងអគ្គិសនី យានដើរគោក (ថលយាន) យានដើរទឹក (ជលយាន) ទាហាន តម្រួត ប៉ូលិស ។

គុណនាម.— ស្តុកស្តម្ភ ម៉ាំមួន ប្រុងប្រាង ធេងធាយ ខ្ពង់ខ្ពស់ ធំធេង ល្វឹងល្វើយ ស្អាត ក្អឹកក្អេក ព្រោងព្រាត ស្រោងស្រើង រៀបរៀង ត្រង់រៀប ស្រស់ ស្រអាត់ រងំ ក្សេមក្សាន្ត ហឹហា កបកាប បំព្រង ល្អយល្អង ប្រិមប្រិយ ។

កិរិយាសព្ទ.— ដើរលេង ត្រាច់ចរ យាត្រា រត់ទៅមក វិញ លក់ ស៊ី ផឹក ជិះ ចរ ត្រួតត្រា ហាមឃាត់ បង្ហាញ នាំផ្លូវ ធ្វើការ សង់ រុះ រើ សែង រែក ជជែក ប្រៀងកំលេង ។

សេចក្ដីរំឭក.— ពាក្យដែលយើងចុះឈ្មោះទាំងប៉ុន្មាននេះ សំរាប់ឲ្យគ្រូរើសយកមកបង្រៀនឲ្យគប់គ្រាន់ក្នុងមួយអាទិត្យ មិនមែនប្រើឲ្យតែអស់ក្នុង ១ ខណៈដូច្នោះឡើយ ពាក្យទាំងនេះគ្រាន់តែជាលំនាំទេ ឯការបង្រៀនស្រេចលើគ្រូ តែអត្ថនៃពាក្យនោះ ទោះជាពាក្យងាយ ៗ ក៏ដោយ គ្រូតែឲ្យសិស្សយល់ជាប្រាកដ ។

ក្នុងខណៈរៀនមួយ ៗ គ្រូឲ្យពាក្យតែ ៤ ឬ ៦ ម៉ាត់ជានាម ៤ ឬ ៦ ម៉ាត់ជាគុណនាម ៤ឬ៥ ម៉ាត់ជាកិរិយា ក៏ល្មមហើយ ។

ភាសា.— អ្នកមានស្គាល់ទីក្រុងណាមួយទេ? នៅទីក្រុងនោះអ្នកឃើញអ្វីខ្លះ? អ្នកឃើញផ្ទះនៅទីក្រុងយ៉ាងដូចម្ដេច? ផ្លូវយ៉ាងដូចម្ដេច? ទីក្រុងនោះតើជាអ្វី? (... ជាទីប្រជុំជន)? ទីក្រុងនិងស្រុកស្រែប្លែកគ្នាយ៉ាងដូចម្ដេច? ទីក្រុងធំនៃប្រទេសខ្មែរមាននាមហៅអ្វី? ។

## បង្រៀនមើល-ហាត់ភាសា

### ក្រុងភ្នំពេញ

*សៀវភៅវិជ្ជាខេមរភាសាអាទិកដ្ឋានទំព័រ ១២២*

សូមពន្យល់ពាក្យដែលជានាម- គុណនាម-និងកិរិយាសព្ទផង

សូមតម្រូវពាក្យខ្លះ.— រង់រឿងជា រុងរឿង ។ លប់ = លុប ។

**ហាត់ភាសា.-** អ្នកដែលទៅក្រុងភ្នំពេញឬទេ? ភ្នំពេញគឺជាអ្វី? ក្រុងភ្នំពេញនៅកន្លែងណា (...នៅទន្លេបួនមុខ) កាលពីដើមទីកន្លែងក្រុងភ្នំពេញយ៉ាងដូចម្ដេច? សព្វថ្ងៃនេះក្រុងភ្នំពេញយ៉ាងណា? ថ្នុកក្រពាំងទៅណាអស់ទៅ? មានអ្វីជំនួសឡើង? មានគេហស្ថានជាតិអ្វីខ្លះនៅក្រុងភ្នំពេញ? គេហស្ថាននោះយ៉ាងដូចម្ដេច? អ្នកចង់ទៅលេងក្រុងភ្នំពេញឬទេ? ហេតុអ្វី ។

**ការហាត់សរសេរ.—** ចូរធ្វើឃ្លានឹងពាក្យខាងក្រោមនេះ

ទីក្រុងធំ- គេហស្ថាន និមិត្ត

## សរសេរតាមសូត្រ

### ក្រុងភ្នំពេញ

សៀវភៅដែលទំព័រ ១២២ ។ សូមរំលែកមេរៀននេះជាពីរផ្នែក ។ ផ្នែកទី ១ តាំងពី មានទីក្រុងតិច... រហូតដល់ឲ្យបានចម្រើនរុងរឿងឡើង ។ ផ្នែកទីពីរ តាំងពីទីនឹងលុបថ្នុកក្រពាំង រហូតដល់ចប់ ។

**សរសេរពាក្យពិបាកឲ្យសិស្សចំណាំ** — រុងរឿង-ផុស-ព្រះធរណី និមិត្ត - សុទ្ធតែ - ថ្នុកក្រពាំង - សុខក្សេមក្សាន្ត - សង់គេហស្ថាន ។

### តែងសេចក្ដី

ចូរឆ្លើយឲ្យប្រកបនឹងពាក្យសួរខាងក្រោមនេះ

ទីក្រុងជាទីប្រជុំយ៉ាងដូចម្ដេច? អ្នកឃើញមានអ្វីខ្លះក្នុងទីក្រុង? គេហស្ថាន និងផ្លូវថ្នល់ នោះតើយ៉ាងដូចម្ដេច? គេឃើញមានបណ្ដាជនយ៉ាងដូចម្ដេច ៗ

សេចក្ដីរំឭក.— ក្នុងការបង្រៀនតែងសេចក្ដី សុំកុំភ្លេចឲ្យសិស្ស ឆ្លើយមាត់ទទេជាមុន ។

## អក្សរផ្ចង់

ប ប ម ហ ឋ

ប បា បី បូ បួ បើ បៀ បែ បៅ បោ

បំបុ បំប៉ា បំបៅកូន បំប៉នបំណី បំបែក

## អាទិត្យទី ២

## បង្រៀនពាក្យ-ហាត់ភាសា

### អំពីទីក្រុង (ត)

នាម.— ព្រះបរមរាជវាំង ព្រះករុណា ព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះទីនាំងចន្ទឆាយា ព្រះទីនាំងភោជនីយ ព្រះមហាប្រសាទខេមរិន្ទ ព្រះដំណាក់ផៃ ៗ ស្វេតច្ឆត្រ ព្រះបល្ល័ង្ករាជ្យ ៗ ព្រះខាន់រាជ្យ ព្រះទីនាំងសំរិទ្ធិវិមាន ព្រះទីនាំងសម្រាន្តភិរម្យ ។

គុណនាម.— រុងរឿង ថ្កុំថ្កើង ប្រពៃ ស្អាត ធំ ទូលាយ ប្រសើរ

កិរិយាសព្ទ.— ស្អាង ថ្វាយ គាល់បំរើ យាងទៅ គង់នៅ ផ្ទំ សោយ ស្រង់ ទត ប្រទាន ។

**ហាត់ភាសា.—** អ្នកដែលឃើញព្រះបរមរាជវាំងឬទេ? ព្រះបរម-រាជវាំងនោះនៅឯណា? ព្រះបរមរាជវាំងនោះជាអ្វី? នៅក្នុងព្រះបរមរាជវាំងអ្នកឃើញមានអ្វីខ្លះ? ប្រាសាទនិមួយៗ តើគេសំរាប់ធ្វើអ្វី? ក្នុងព្រះរាជពិធីបុណ្យអុំទូក (អកអំបុក-សំពះព្រះខែ) ព្រះករុណាស្តេចយាងទៅគង់នៅឯណា? ព្រះករុណាជាម្ចាស់ជីវិតលើត្បូងសព្វថ្ងៃនេះ ទ្រង់ឡើងសោយរាជ្យសម្បត្តិពីថ្ងៃណា? (៤ ៗ ១២ ៥ ឆ្នាំម្សាញ់ត្រីស័ក ព.ស. ២៤៨៤ ត្រូវនឹងថ្ងៃ ២៣-៤-៤១

**ការហាត់សរសេរ.—** ចូរបំពេញពាក្យឲ្យពេញត្រឹមត្រូវនៅកន្លែងចន្លោះខាងក្រោមនេះ ។

នៅក្រុងភ្នំពេញចំទន្លេចតុមុខ មានព្រះ... ព្រះករុណាជាម្ចាស់ជីវិតលើត្បូងយ៉ាងរុងរឿង ។ ក្នុងព្រះបរមរាជវាំងមានព្រះរាជមន្ទីរជាច្រើនគឺ..... ខាងក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ មានព្រះ... ដំកល់.. ប្រាំបួនជាន់ ។ នៅមុខព្រះបរមរាជវាំង ខាងមាត់ទន្លេមាន.... សំរាប់ព្រះករុណាយាងទៅគង់ក្នុងព្រះរាជពិធីបុណ្យអុំទូក (សំពះព្រះខែ) តាមទំនៀមទំលាប់ ។

## បង្រៀនមើល

### ទីក្រុងនិងស្រុកស្រែ

សៀវភៅវិជ្ជាខេមរៈអាទិកជ្ជនទំព័រ ៦៧

**ហាត់ភាសា.—** សំរិតនៅឯណា? ត្រូវជាអ្វីនឹងរិម? រិមនៅឯណា?

សំរិតសរសេរសំបុត្រទៅគិមថាយ៉ាងណា? អ្នកដែលឃើញពន្លឺភ្លើងអគ្គិសនីឬទេ? ពន្លឺនោះយ៉ាងដូចម្ដេច? គិមសរសេរសំបុត្រឆ្លើយទៅសំរិតវិញថា យ៉ាងណា? គិមថា ទីងនាំសំរិតទៅបេះផ្លែឈើអ្វីខ្លះ? ដើរទៅលេងនៅទីណា? ព្រោះហេតុអ្វី? អ្នកចូលចិត្តនៅទីក្រុងឬនៅស្រុកស្រែ? ហេតុអ្វី?

ការហាត់សរសេរ.— សូមធ្វើតាមការហាត់ក្នុងមេរៀននេះ នៅទំព័រ ៦៨ ។

## សរសេរតាមសូត្រ

សូមយកសេចក្ដីដែលបង្រៀននេះ មកដាក់ឲ្យសិស្សសរសេរតាមគ្រូថាផង ប៉ុន្ដែត្រូវចែកជាពីរផ្នែក ។ ឬចង់តែងសេចក្ដីដូចខាងក្រោមនេះឲ្យសិស្សសរសេរតាមក៏បាន ។

### ព្រះបរមរាជវាំង

នៅក្រុងភ្នំពេញមានព្រះបរមរាជវាំងថ្កើងរុងរឿងណាស់ មានកំពែងឥដ្ឋខ្ពស់ ហើយក្រាលព័ទ្ធជុំវិញ ខ្លោងទ្វារខាងកើត បែរចំទៅទន្លេចតុមុខ ។ ក្នុងព្រះបរមរាជវាំង មានព្រះទីនាំងទេវាវិនិច្ឆ័យធំទូលាយ ដ៏ល្អស្ងប់ស្ងែង ដំបូលឡើងជារូតមានរូបគ្រុឌទ្រ ។ ខាងក្នុងកំពូលមានព្រះភក្ត្រព្រហ្មញញឹមទៅទិសទាំងបួន ហើយមានកំពូលត្រីសូលខ្ពស់ស្រួច ។ ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យមានព្រះបល្ល័ង្កជ្រងមានស្វេតច្ឆត្រប្រាំបួនជាន់គ្របពីលើ ។ នៅកំពែងខាងក្នុងមានព្រះមហាប្រាសាទខេមរិន្ទ គឺជាដំណាក់សម្រាប់ព្រះករុណាជាម្ចាស់ជីវិតលើត្បូងគង់នៅ ។ល។—

សរសេរពាក្យពីបាក ។— *បរមរាជវាំង - ឥដ្ឋ - ព័ទ្ធ - បុស្បុក - ព្រះភក្ត្រព្រហ្ម - ត្រិសូល៍ - បល្ល័ង្ក - ស្វេតច្ឆត្រ ។*

## តែងសេចក្ដី

*ចូរអ្នកសរសេរសំបុត្រមួយច្បាប់ផ្ញើទៅមិត្តសំឡាញ់អ្នក ដែលនៅស្រុកស្រែ និយាយអំពីសេចក្ដីសប្បាយគ្រប់យ៉ាង —*

*— សេចក្ដីផ្ដើម*

*— សេចក្ដីកប់រៀប : អំពីកំនល្អ - ផ្លូវថ្នល់ - ផ្សារ - មន្ទីរផ្សេងៗ (ផ្ទះកងការ - សាលារៀន - ពេនល្បា) ។*

*— សេចក្ដីបញ្ចប់ : (ញ៉ាំងមិត្តសំឡាញ់អ្នកឲ្យចង់ចូលទៅមើលទីក្រុង) ។*

### អក្សរផ្ចង់

ប ប ម ហ បិ

ម មា មី មូ មួ មើ មឿ មៀ មេ មែ មៅ មុំ
មំ មាំ មមីមមើ មេមុំមួមៅ កើតមោហៈ ។

## អាទិត្យទី ៣

## បង្រៀនពាក្យ-ហាត់ភាសា

### ទីក្រុង (ត)

នាម.— ហាងទំនិញ ពាណិជ (ជំនួញ, អ្នកជំនួញ) អម្ពរពស្ត្រ (សំពត់) គន្ធពាណិជ (អ្នកជំនួញទឹកអប់) ពាណិជកម្ម (ការធ្វើរបរលក់ដូរ) ពាណិជការ (អ្នកធ្វើការជំនួញក្រសួងត្រួតត្រាជំនួញ) អាហារ ចំណី យាន ទោចក្រ ត្រីចក្រ រថ រទេះ រថយន្ត កង់អ៊ូ ឬ កង់ចក្រ គោម ប្រទីប អគ្គិសនី ខ្សែលួសភ្លើង ម៉ាស៊ីនទឹក កប៉ាល់ ទូក កាណូត ថ្ម ប៉ុកបាយ ។

គុណនាម.— ចំណេញ ខាត ក្រអូប ល្អ បរិបូណ៌ ឆ្ងាញ់ ប្រសើរ ថ្លៃក រហ័ស ឈ្មួរ កកកុញ តានតាប់ ។

កិរិយាសព្ទ.— ទៅ មក ចេញ ចូល លក់ ទិញ តថ្លៃ ជិះ ដើរ បរ ដាក់ វិល បំភ្លឺ ទាញកញ្ចប់ បត់ ចាប់ចង្កូត បើកភ្លើង ដឹកទំនិញ បញ្ជូន កាល់ ជូន ផែន ដូរ រែក ......។

ការហាត់.— ចូរឆ្លើយឲ្យប្រកបនឹងពាក្យចោទខាងក្រោមនេះ អ្នកដែលទៅហាងទំនិញឬទេ? អ្នកត្រូវការទិញវត្ថុអ្វីខ្លះ? អ្នកជំនួញទឹកអប់ហៅថាអ្វី? ចុះអ្នកធ្វើការជំនួញ ឬក្រសួងត្រួតត្រាជំនួញហៅថាអ្វី? យានមានកង់ពីរ គេហៅថាអ្វី? មានកង់បីហៅថាអ្វី? បើគេដើរដំណើរតាមដីគោក គេប្រើយានអ្វីខ្លះ? តាមដែនទឹកគេប្រើយានអ្វីខ្លះ? ។

## បង្រៀនមើល

### ចិននៅក្នុងប្រទេសឥណ្ឌូចិន

សៀវភៅខេមរភាសាដដែលទំព័រ ២០

**សុំជម្រើសពាក្យ.–** សាស្ត = ជា សាសន៍ ។ ភូម៌ = ភូមិ សុំរើសពាក្យដែលជានាមគុណនាមនិងកិរិយា ដាក់ឱ្យសិស្សរៀនផង ។

**ហាត់ភាសា.–** នៅប្រទេសឥណ្ឌូចិន មានសាសន៍ដទៃអ្វីច្រើនជាងគេ ? ចិនមកពីទេសណាខ្លះ ? កូនចៅចិនដែលតាំងទីលំនៅយូរឆ្នាំនៅប្រទេសឥណ្ឌូចិនហៅថាអ្វី ? ចិនមានចិត្តយ៉ាងណាក្នុងការរកស៊ី ? ចិននៅស្រុកខ្មែរច្រើនហើយរកស៊ីអ្វី ? ចិននៅក្រុងភ្នំពេញរកស៊ីអ្វី ? សាសន៍ណាធ្វើជំនួញ ? ការជំនួញរបស់ចិនបានចំរើនឬទេ ? ប្រាក់ចំណេញវាយកទៅណា ? អ្នកពលគ្នាត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីនឹងចៀសវាងកុំឱ្យចិនបោកបាន ។

## សរសេរតាមសូត្រ

សុំយកសេចក្ដីមើលខាងលើនេះដាក់ឱ្យសិស្សសរសេរតាមគ្រូថាផង ឬនឹងធ្វើតាមសេចក្ដីខាងក្រោមនេះក៏បាន ។

### អំពីផ្ទះលក់ទំនិញ

កាលពីថ្ងៃអាទិត្យមុននេះ ខ្ញុំជូនម្ដាយខ្ញុំទៅទិញសំពត់ព្រែនៅហាងលក់ទំនិញមួយខាងលិចផ្សារធំថ្មី ។ នៅក្នុងហាងនោះខ្ញុំឃើញគេដាក់ទូកញ្ចក់វែងភ្ជាប់ទៅជញ្ជាំងតាំងសងខាង ជិតមាត់ទ្វារចូលមានតុមួយដែលសម្រាប់ទទួលប្រាក់ ក្នុងទូកញ្ចក់និមួយៗមានដាក់វត្ថុច្រើន ដូចជា មួក ឆ័ត្រ ស្បែកជើង ទឹកអប់ សំពត់ព្រែខៀវនិងព្រែផ្កាដ៏មានពណ៌ផ្សេងៗ ។ នៅមុខទូខ្ញុំឃើញមានបានគ្រប់យ៉ាង ពែងតូច-ធំ ហើយនឹងឆ្នាំងស្ពាន់-ដែក ។

សរសេរពាក្យពីបាក. *កញ្ចក់ - ក្លាច់ - ជញ្ជាំង - ទ្វារ - តុ - គ្រែ - ពណ៌ - ស្ពាន់ - ដែក ។*

## តែងសេចក្ដី

*ចូរអ្នកអធិប្បាយអំពីហាងចិនលក់ទំនិញមួយ ដែលអ្នកបានស្គាល់ជាប្រាកដ ។*

*តើផ្ទះនោះសង់ដូចម្ដេច? ធ្វើអំពីអ្វី? នៅក្នុងហាងនោះអ្នកឃើញទំនិញអ្វីខ្លះ? គេរៀបចំលក់បែបយ៉ាងណា? យោបល់របស់អ្នកដែលយល់ឃើញអំពីហាងចិនលក់ទំនិញនោះ? ។*

## អក្សរផ្ចង់

សុំធ្វើផ្គួចអាទិត្យមុខ ប៉ុន្តែត្រូវយកអក្សរ "ហេ-ឋ" ប្រើជាពាក្យ

## អាទិត្យទី ៤

សុំសាបង្រៀនគ្រប់វិជ្ជាទាំងអស់ តាំងពីអាទិត្យទី ១ ឡើងវិញ

## មេសូត្រត់មាត់

បរិច្ឆណដ្ឋាន

### ការធ្វើស្រែ

រីឯស្រែចំការ គួរពិចារណាឲ្យឃើញគុណ កិច្ចនេះប្រសើរស៊ុន

បុរាណមុនលោកសឹងរាប់ ។ ជីវិតយើងសព្វថ្ងៃ តែងអាស្រ័យ
អាហារជាប់ ទោះទាំងសម្បត្តិទ្រព្យ ជាប់តែបានផលពីស្រែ ។
បំណែកបំការនោះ ច្រើនបណ្តុះឈើស៊ីផ្លែ ស្លឹកឈើធ្វើបន្លែ ជា
អន្លក់គ្រប់ប្រការ ។

---

សព្ទពន្យល់– គួរវិចារណ៍ = គួរគិត ។
ប្រសើរស៊ុន = ប្រសើរពេក ឬ ស៊ុនពេក ។
(ប.ឆ.)

---

## ការធ្វើស្រែ (គ)

ផ្តើមហេតុនេះឲ្យស្គាល់ ដល់ទៅផលធញ្ញាហារ វិសេស
យ៉ាងអស្ចារ្យ ជាសារៈប្រយោជន៍ធំ ។ ជាតិយើងចិញ្ចឹមជន្ម
ក្នុងប្រពន្ធគ្រប់និគម កុំភ្លេចជាមុខធំ នោះគឺធ្វើបំការស្រែ ។
យើងធ្វើកើតទាំងម្ល៉េះ គង់នៅបេះមិនពូកែ សហរដ្ឋប្រើសុទ្ធតែ
គ្រឿងយន្តតាងគោក្របី ។

---

សព្ទពន្យល់– ផលធញ្ញាហារ = ផលស្រូវជាអាហារ ។
សារៈប្រយោជន៍ = ជាខ្លឹមរបស់ប្រយោជន៍ ។
សហរដ្ឋ = មហានគរ ។
(ប.គ.)

អានិកដ្ឋានទី៥មជ្ឈមដ្ឋានទី ១

## បំហាយក្ដៅក្នុងដី

អ្នកតែងសៀវភៅ បំណោះលោកជ្រៅ ហើយលោកបានជ្រាប
គ្រប់សព្វវិធី អំពីសភាព ផែនដីខ្ពស់ទាប តាមដោយកន្លែង ។
លោកថាទីខ្លះ ទឹកជ្រោះហូរជះ ចេញពីក្រហែង ដីមកបំកោយ
ក្ដៅខ្លាំងក្រៃលែង ឧប្បត្តិឡើងឯង ផ្សែងហុយហាក់ឆេះ ។ ដោយ
ក្នុងដីក្ដៅ ខ្លាំងជាងផ្ទៃក្រៅ ប្រាកដដូច្នេះ ខ្លាំងឡើងសុសសាយ
បំហាយក្ដៅនេះ ជិតទៅប្រែបេះ បៀតដល់ស្ទូលដី ។

---

សព្ទពន្យល់— វិធី = បែប, បែបយ៉ាង ។

សភាព = ដំណើរកើតឯង ។

ឧប្បត្តិ = ការកើតឡើង ។

(ប.ត.)

---

## បំហាយក្ដៅក្នុងដី (ត)

ជំរៅមួយរយ គីឡូម៉ែត្រដោយ បានស្ទង់ដើម្បី ឲ្យដឹងកំដៅ
ដែលនៅក្នុងដី ផែនភពលោកី បីពាន់កំរិត ។ នៃកែវស្ទង់ជាតុ
បញ្ជាំងមើលជាតិ ដីជាក់ស័ក្ដិសិទ្ធ ឃើញជារបស់ ក្ដៅអស់ពីចិត្ត

វត្ថុរឹងស្វិត ដូចជាបាសាណ ។ ក៏អាចឲ្យជ្រាយ រលួយដោយងាយ រលាយគ្នាបាន ហើយរាវហៀរហូរ ជោរទឹកមិនខាន ក្តៅនេះតាមស្ថាន គ្មានក្តៅអ្វីស្មើ ។

---

សព្ទពន្យល់– ភព = ទាំងពីភពលោក ។

ស័ក្តិសិទ្ធិ = ដែលខ្លាំងពូកែ ។

បាសាណ = ថ្ម ។

(ប.គ.)

---

### មជ្ឈិមដ្ឋាននិងឧត្តមដ្ឋាន

## សេចក្តីសុចរិតក្នុងការជំនួញ

ពាណិជ្ជកម្ម កិច្ចនេះបំណាំ តែយកបំណោញ លោភលើសបំនួន ដើមទុនដែលចេញ ទទួលទំនិញ ទិញថោកលក់ថ្លៃ ។ ផ្លូវលោភរកលាភ កាត់ខ្ពស់លស់ទាប នឹងទារកម្រៃ មិច្ឆាជីវៈ អស័ត្យវិស័យ ឥតអធ្យាស្រ័យ អធ្យោគយោគយល់ ។ សម្មាជីវៈ វាចាសច្ចៈ គ្មានបង់រវល់ បិញ្ចឹមជីវិត បិទភ្នែកបុគ្គល អ្នកទិញគ្មានយល់ កលកោងកាប់កាប ។

សព្ទពន្យល់ -- មិច្ឆាជីវ: = ចិញ្ចឹមជីវិតអាក្រក់ ។

អសត្យ = មិនសុច្ចរិត ។

សម្មាជីវ: = ចិញ្ចឹមជីវិតល្អ ។

សច្ច: = ទៀងត្រង់ ។

កោងកាច់ ឬកុងកាច់ = បំបាត់ប្រែវិញ ។

(ប.ត.)

---

## សេចក្ដីសុចរិតក្នុងការជំនួញ (ត)

ជញ្ជីងភ្នែកខ្វះ សង្កត់បំបះ កូនតឹងសំងាប ឲ្យឃើញធ្ងន់វិញ អ្នកទិញបាត់ប្រាជ ពារលើមនុស្សកាច គេតឈ្មោះទាស់គ្នា ។ ង្វាស់រង្វាល់ ក្រាម-លីត្រវៀងដល់ គីឡូដែលជា របស់រាជការ រអាររួញរា បំពោតបំពា បំពានលើច្បាប់ ។ អ្នករៀនទាំងឡាយ ឮបរិយាយ នេះហើយប្រុងស្ដាប់ បើបានធ្វើជា ពាណិជ្ជកុំត្រាប់ ត្រូវជួញតាមច្បាប់ សណ្ដាប់សួតត្រង់ ។

---

សព្ទពន្យល់ -- បំពោត = បញ្ឆោតកុហក់ ។

បរិយាយ= សំដែង ។

# រឿងមើលកំសាន្ត

ឆាទន៍កពារចាស់ (គ)

មើលន៍មនោ នែមជ្ឈរោ យោគ្យភាពរាត ត្បាតគន់បន្តែ ប្រុងតែពីឃាដ មុសិកជាតិ ជាអាបិន្ទ្រ្តិយ ។ បែកពួកកណ្ដុរ ទាំងឡាយកាយស្បុរ ស្វែងឫទ្ធិក្រៃ នៅតែក្នុងរន្ធ ឥតពន្លឺថ្ងៃ ធន់អត់អាស្រ័យ វិស័យជាប់គុក ។ ពុំហានចេញមក ក្រៅវាលដើររកបំណីបំណុក ទ្រាំអត់ទ្រាំឃ្លាន គ្មានបង់ជួបមុខ ព្រោះខ្លាចទង្គុកបង្គមឆ្មាខាំ ។

---

សព្ទពន្យល់- មនោ = ចិត្ត ។

មជ្ឈរោ = ឆ្មា ។

យោគ្យភាព = ម.ចំ. យោគ្យៈភាពៈ ការស្គាត់ជំនាញ, ការថ្នឹកប្រសព្វ ។

(ប.គ)

អានិកដ្ឋាន

**នព្វន្ត**

អានិក្យទី ១.— ចំនួនពីមួយរយដល់មួយពាន់

## លេខចែកនឹងមេលេខ៥ ហើយនឹង៦

(មើលតាមក្បួនក្នុងអាទិកដ្ឋាន ទំព័រទី ៣៤)

ដូចជា : ៣៥ : ៥= ..... ៤៨ : ៦= .......

គេគិតយ៉ាងនេះ ៣៥ : ៥= ៧ ; ៤៨ : ៦= ៨

## ការហាត់សរសេរ

៣៥ម : ៥= ..... ២៤ម : ៦= ..... ៤២រ : ៦= .....

២០រ : ៤= ...... ៣៦ម : ៦= ..... ៣០ : ៦= ......

## លំហាត់ទី២.– លេខគុណនឹង៧ ហើយនឹង៨

(មើលតាមក្បួនក្នុងដែលនៅទំព័រទី ៤៤ )

ដូចជា : ៦ × ៧= ...... ៩ × ៨= ......

គេគិតយ៉ាងនេះ : ៦ × ៧=៤២ ; ៩ × ៨= ៧២

ការហាត់សរសេរ.– សុំឲ្យសិស្សធ្វើលេខដែលបានបង្រៀនរួច ហើយ ៗ –

## លំហាត់ទី៣.– លេខគុណលេខមេគុណមានលេខពីរតួ

ដូចជា ២៤ × ១២=

គេគិតយ៉ាងនេះ ២៤ × ១២ = ២៨៨

វិធាន.– គេធ្វើលេខគុណ លេខមេគុណមានពីរតួ ដូចជាគេធ្វើ លេខតែមួយតួដែរ (សុំមើលតាមក្បួនក្នុងនៅទំព័រទី ៩២ –

*អាទិត្យទី ៤.—* អំពីលេខគុណ (មេគុណមានលេខពីរតួ)

សុំសាបង្រៀនឡើងវិញដូចមេរៀនពីអាទិត្យទី ៣ ។

## ការហាត់សរសេរ

| | | | |
|---|---|---|---|
| ៣៥ម | ៦៩ម | ៤១រ | ៣៧រ |
| × ១៣ | × ២៤ | × ២៣ | × ១៨ |

បំណោទ.— *ចៅសួនទិញគោ ២៤ គោមួយថ្លៃ ៣៩ រៀល លក់ទៅវិញបានទាំងអស់ ១២៦៥ រៀល តើចៅសួនចំណេញបានប៉ុន្មាន រៀល ។*

## រង្វាស់រង្វាល់

*អាទិត្យទី ១.—* អំពីហិកតូម៉ែត្រ

*(មើលក្នុងក្បួនទន្ទេញ អាទិកដ្ឋានទំព័រទី ៤៣)*

## វិធីហាត់សរសេរ

ក្នុងហិកតូម៉ែត្រមាន.........ម៉ែត្រ........ដេការម៉ែត្រ ។

ក្នុង ៥ ដេការម៉ែត្រនិង ៩ ម៉ែត្រមាន.......ម៉ែត្រ ។ ...........

*អាទិត្យទី ២.—* អំពីហិកតូលីត្រ ហិកតូក្រាម

*(មើលក្នុងក្បួនទន្ទេញដែលនៅទំព័រទី ៥២)*

*ការហាត់សរសេរសុំជ្រើសរើសឲ្យល្មមកំរិតសិស្ស ។*

អាទិត្យទី ៣ .— អំពីរង្វាស់រង្វាល់ខ្មែរ

( សុំមើលតាមក្បួននព្វន្តដែលទំព័រទី ១១១ )

១ — អំពីនាឡិ ចុង ហាប

២ — ដំឡឹង ជី ហ៊ុន លី

អាទិត្យទី ៤.— សូមសាបរៀនអំពីរង្វាស់រង្វាល់ដែលបានដាក់ឲ្យរៀន ហើយតាំងពីអាទិត្យទី ១ – ២ – ៣ មក ។

---

បរិច្ឆណាដ្ឋាន

## នព្វន្ត

### ចំនួនពី ១ ដល់ ១០០

ដប់ ១០ ដងមួយរយ គេសរសេរមួយរយដូច្នេះ (១០០) និងរាប់លេខពី ១ ដល់ ១០០វិញនោះ គេរាប់ដូចជាពី ១ ដល់ ១០ ដែរ តែពី ១០ ឡើងទៅគេថាដប់មួយ ដប់ពីរ ដប់បី.... ម្ភៃ.... ម្ភៃមួយ ម្ភៃពីរ....។ល។ រហូតដល់កៅសិប កៅសិបមួយ កៅសិបពីរ ។ល។ កៅសិបប្រាំបួន មួយរយ (១០០) ។

## វិធីហាត់មាត់ទទេ

ត្រូវមានឪប់ប៉ុន្មានផងហើយនឹងរាយប៉ុន្មាន ទើបបាន ៦៧-៩៣-៩៩-១០០ ។ រាប់ចំនួនគត់គូពី៦០ដល់៨០ ។ ពី៨០ ដល់១០០ ។ រាប់ចំនួនសេសពី៧៩ដល់៩៩ (៧៩-៨១-៨៣-៨៥ ។ល។ នៅសេសប៉ុន្មាន ៣៨កាត់១២ ។ ៦៧កាត់ ២៥ ។ ៩៩កាត់ ៧៦ ។ល។

## បំណោទ

ក្នុងសាលារៀនមួយមានកូនសិស្ស៨៩នាក់ អង្គុយក្នុង ៣ បន្ទប់ ក្នុងបន្ទប់ទី ១ មានកូនសិស្ស២៣នាក់ បន្ទប់ទី ២ មានកូនសិស្ស ២៩ នាក់ តើបន្ទប់ទី ៣ មានកូនសិស្សប៉ុន្មាននាក់ ។

សូមលៃថែមការហាត់សរសេរលេខ នឹងបំណោទឲ្យសិស្សធ្វើផង ។

## លេខគុណនឹង៨:

គ្រូឲ្យបង្កើះ ៧ ម្នាក់ទៅសិស្ស៨នាក់ តើទាំងអស់ត្រូវបង្កើះប៉ុន្មាន បើខ្ញុំគិតចំនួននេះដោយគំនិតនោះ ខ្ញុំថាប្រាំបីមួយដង ប្រាំបីថែមប្រាំបីត្រូវជា១៦ តរៀងទៅដល់៥៨ ថែមប្រាំបីត្រូវ

៥៦ ឬ ៨ ប្រាំពីរដងត្រូវជា ៥៦ គេសរសេរតាំងលេខយ៉ាងនេះ ៨ × ៧ = ៥៦ ត្រូវដាក់មេលេខគុណនឹង ៨ ឲ្យសិស្សរៀនឲ្យចាំស្ទាត់ផង ។

*វិធីហាត់មាត់ទទេ* — ត្រូវជាប៉ុន្មានស្លាបប៉ាកកា ៤ ប្រាំបីដង ។ បេះ បីស្មិតប្រាំបីដង ។ ដីស ៧ ដុំ ៨ ដង ។ល។ ខ្មៅដៃ ១ ថ្លៃ ២ រៀល ខ្មៅដៃ ៨ ថ្លៃប៉ុន្មាន ។ល។ សុំឲ្យចោទសួរពីមេលេខគុណពីមេ-២-៣-៤-៥-៦-៧ ដូចជា ២ ពីរដង, ៣ ពីរដង ។ល។ ៧ បីដង ត្រូវជាប៉ុន្មាន ។

បំណោទ

ជាងឈើម្នាក់លក់តុៈសរសេរ ៧ ថ្លៃមួយ ៨ រៀល ហើយនឹងកៅអី ៨ ថ្លៃមួយ ៤ រៀល ទាំងអស់ជាងនោះលក់បានប្រាក់ប៉ុន្មាន ។ បំណោទនេះ សូមលោកគ្រូលៃរបស់ណាល្មមដម្លៃ ៨ រៀល ៤ រៀល ឲ្យសិស្សធ្វើតាមនិយមសម័យ ។

អំពីចំនួនរយនឹងវិធីហាត់សរសេរ

របស់អ្វី ១០ ដប់ដងហៅថារបស់មួយរយ ។ មួយរយដប់ដងហៅថាមួយពាន់ (១០០០) ។ ឯរបៀបរាប់ចំនួនរយក៏ដូចជាចំនួនរាយ

ដែរ គេថា ១រយរៀល ពីររយរៀល បីរយសេន បួនរយ........ រយ...... ១រយ...... ឬ១ពាន់ (១០០០) ។

*វិធីសរសេរចំនួន*.— ចំនួន ពី ១ ដល់ ៩ លេខមានតែមួយតួ (ខ្ទង់រាយ) ពីដប់ដល់៩៩លេខមានតែពីរតួ ឬ ពីរខ្ទង់ (ខ្ទង់រាយ នឹងខ្ទង់ដប់) ។ ពី១០០ដល់៩៩៩លេខមានតែ ៣ ខ្ទង់ ឬ៣ តួ ខ្ទង់ទី១ខាងស្ដាំហៅថាខ្ទង់រាយ ខ្ទង់ទី២ខាងឆ្វេងចំនួនរាយ គឺ ខ្ទង់ដប់ ។ ខ្ទង់ទី៣ខាងឆ្វេងចំនួនដប់ គឺចំនួនរយ រួមទាំង ៣ខ្ទង់ គេហៅពីស្ដាំទៅឆ្វេងថាខ្ទង់រាយ ខ្ទង់ដប់ ខ្ទង់រយ ក្នុង ចំនួននេះបើខ្វះខ្ទង់ណាមួយនោះ គេដាក់លេខសូន្យជំនួស ដូច ៤០៣សេន ។ល។

*វិធីហាត់អានលេខ*.— សុំថាចំនួនដែលមានលេខ៣ខ្ទង់ឲ្យសិស្ស សរសេរទៅលើក្ដារខ្មៀន រួចលើកបង្ហាញគ្រូមើលរួចសួរឲ្យឆ្លើយ ក្នុង ចំនួននេះមានចំនួនរាយ ដប់ ឬរយប៉ុន្មាន ។ ឲ្យរាប់បន្ថែម ឬ ដក បន្ថយតាមចំនួនដែលគ្រូថា ។

*វិធីហាត់សរសេរ*.— ឲ្យសរសេរជាលេខដប់បួន ។ សាមសិប ប្រាំ ។ ចិតសិបប្រាំបួន ។ល។

## បំណោទ

ជង្ហៅបិនម្នាក់ទិញទូកមួយ ថ្លៃ ១២៣ រៀល លក់ទៅវិញថ្លៃ ១៤០ រៀល ។ តើជង្ហៅនោះបានបំណេញប៉ុន្មាន ។

## បំនួនពី ១០០ ដល់ ២០០

សុំឲ្យរករត្តុយកមកឲ្យសិស្សរាប់ដូចបង្កើះដុំគ្រួស ។ ឲ្យរាប់បំនួនពី ១០១ ដល់ ១៩៩ ពីររយ (០០) សរសេរលេខដូច្នេះ ១០១-១០២........ ១៩៩-២០០ ។

*វិធីហាត់ទាត់ខ្លួន* — ឲ្យរាប់បន្ថែមប្រាំៗ ពី ១០០ ដល់ ២០០ ។ បន្ថយប្រាំៗ ពី ២០០ ដល់ ១០០ ។ ត្រូវជាប៉ុន្មាន ៤០ នឹងដប់ ។ ៨០ នឹង ៣០ ។ ល ។ ១០០ ដក ២០ ។ ១២០ ដក ៣០ ។ ១៨០ ដក ១១០ ។ ល ។

## បំណោទ

ម្ដាយខ្ញុំទៅផ្សារគាត់ទិញម្ហូបនឹងបន្លែគ្រប់មុខអស់ ១៨រ. ទិញសំពត់ ១ ម៉ែត្រអស់ ៣២ រៀល ទិញបាន ១ ឡអស់ ៤៨ រៀល ។ តើម្ដាយខ្ញុំចាយអស់ប្រាក់ប៉ុន្មានរៀល ។

— លេខចែកនឹង ៥

ខ្ញុំមានដុំគ្រួស ២០ ដុំ ខ្ញុំចែកឲ្យក្មេង ៥ នាក់ តើម្នាក់ត្រូវបានប៉ុន្មាន ។

ដើម្បីរកបំណែកក្មេងម្នាក់ៗនោះ ត្រូវយកចំនួន ២០ មកចែក នឹង ៥ គេតាំងលេខដូច្នេះ ២០ : ៥ = ៤ ឬក៏

| | | |
|---|---|---|
| ២០ | ៥ | ។ល។ |
| ០ | ៤ | |

សូមមើលកិច្ចសិក្សាទី ១១ លេខ ៤ ទំព័រ ២៣

---

បរិច្ឆណាដ្ឋាន

## រង្វាស់រង្វាល់

### – គីឡូម៉ែត្រ គ.ម.

គីឡូម៉ែត្រជាខ្នាតមានប្រវែង ០០០ម៉ែត្រ ១០០ដេកាម៉ែត្រ ឬ១០ហិកតូម៉ែត្រ គេសរសេរកាត់ គ.ម គីឡូម៉ែត្រនេះ គឺដូចជាហិកតូម៉ែត្រ ជាខ្នាតមើលមិនឃើញ ឬកាន់មិនបានទេ។ ខ្នាតគីឡូម៉ែត្រនេះ គេប្រើសំរាប់សំគាល់ ពីប្រវែងផ្លូវថ្នល់ ឬ ជុំវិញនគរ ពុំនោះដូចចំងាយពីស្រុកមួយទៅស្រុកមួយ ដូចនៅលើចិញ្ចើមថ្នល់ គេតែងឃើញមានគោលឬគំនូរជាដរាប ។

*វិធីហាត់គិតមាត់ទទេ.—* មួយគីឡូម៉ែត្រមានប៉ុន្មានម៉ែត្រ,ដេការម៉ែត្រ. ហិកតូម៉ែត្រ ។ ត្រូវថែមប៉ុន្មានទៅលើ៦ហ.ម. ទៅលើ ៣១០ម. ៧០ដ.ក.ម ទើបបានមួយគ.ម. ។ ត្រូវជាប៉ុន្មាន៩ គ.ម+៣០០ម=...ម ។ ១៧ហ ម.+ ១៥ ដ.ក.ម=... គ.ម ។ ៧២គ.ម+២០០០ម=.....គ.ម. ។ល ។

បំណោទ

មនុស្សម្នាក់ត្រូវការដើរពីស្រុកមួយទៅស្រុកមួយ បំងាយ៥៦ គីឡូម៉ែត្រ អ្នកនោះដើរបាន ៧ម៉ោង ឥតឈប់សោះ ក្នុងមួយម៉ោងដើរបាន៦គ.ម. តើអ្នកនោះត្រូវដើរប៉ុន្មានគ.ម.ទៀត ទើបបានដល់ ។

សូមលៃបំណោទឲ្យសិស្សធ្វើថែមទៀតផង

*—គីឡូក្រាម. ត. ក្រ.*

សូមយកជញ្ជីងនឹងកូនទម្ងន់គ្រប់បែបមកបង្ហាញសិស្ស រួចបង្រៀនសិស្សឲ្យថ្លឹងសៀវភៅប្រអប់ដីស ដំបូ ដុំឥដ្ឋ ល។ហើយឲ្យសិស្សទាយស្មានទម្ងន់វត្ថុផ្សេង ៗ រួចឲ្យហៅជាក្រាម ដេការក្រាម ហិកតូក្រាម គីឡូក្រាម ។ ឲ្យសិស្សរៀនឲ្យចាំមាត់ស្ទាត់ជា

១ គីឡូក្រាម មាន ១០ ហិកតូក្រាម ១០០ ដ.ក.ក្រ. ១០០០ក្រ. ។ ១០ក្រ. ត្រូវជា ១ ដ.ក.ក្រ. ។ ១០ ដ.ក.ក្រ. ត្រូវជា ១ ហ.ក្រ. ។ ១០ ហ.ត.ក្រ. ត្រូវជា ១.គ.ក្រ. ។

*វិធីឃាត់គិតមាត់ៈ ៤* – យើងមាន ៦០០ក្រ. ៧ ដ.ក.ក្រ. ។ល។ នៅខ្វះប៉ុន្មានទៀតទើបបាន ១ គ.ក្រ. ។ ៣-៤-៥ គ.ក្រ. មានប៉ុន្មានក្រាម ដ.ក.ក្រ. ហ.ក្រ. ។ល។

## បំណោទ

១– អ្នកជំនួញម្នាក់ បានទិញគ្រាប់សណ្ដែកឯពោធិ៍ចិនតុង ៧៩៥ គីឡូក្រាម ដឹកមកដល់ទីកន្លែងលក់អស់ ២៥ គ.ក្រ. ដល់បាក់ទុកបានលក់ ៣ បាវទៀត ក្នុង ១ បាវមានទម្ងន់ ៩០ គ.ក្រ. តើអ្នកជំនួញនោះ នៅសល់សណ្ដែកប៉ុន្មានគីឡូក្រាមទៀត យកទៅលក់ ។

២– អង្ករមួយហិកតូលីត្រទម្ងន់ ៨០ គីឡូក្រាម ការុងមួយប្រកអង្ករបាន ៧០ លីត្រ តើការុង ៣០ ប្រកអង្ករបានប៉ុន្មានហិកតូលីត្រ ហើយទម្ងន់បានប៉ុន្មានគីឡូក្រាម ។

## អំពីកាំងតាល់ហើយនឹងតោន

ទម្ងន់ ១០០០ គីឡូក្រាមហៅថា ១ កាំងតាល់ៗនេះប្រើច្រើន លើសអំពីពីរទៅហៅថាកាំងតូ ។ ទម្ងន់ ១០០០ គីឡូក្រាមហៅថា ១ តោន ។ ទម្ងន់នេះសំរាប់ថ្លឹងរបស់ធ្ងន់ៗ ដូចរទេះឡាន រទេះដែក ឬម៉ាស៊ីន ។ល។ តោននេះសំរាប់កត់បំណុះទូក កប៉ាល់ នាវាទាំងឡាយ ឧបមាដូចជាប៉ុកហាយមួយមានបំណុះ ១៥ត.៧៥០ ។

*វិធីហាត់គិតមាត់ទទេ* — ២០០ គ.ក្រ. ។ ១០០០ គ.ក្រ. ។ ១៥០០ គ.ក្រ. មានប៉ុន្មានកាំងតូ-តោន ។ គីឡូក្រាម ។

### បំណោទ

១ – អ្នកជំនួញម្នាក់ទិញម្រេចបាន ៧០០ បាវ ក្នុង ១ បាវទម្ងន់មួយកាំងតាល់ លក់ទៅវិញអស់ម្រេច ៣ ៥០០ គ.ក. តើនៅសល់ម្រេចប៉ុន្មានកាំងតាល់នឹងគីឡូក្រាមទៀត ។

---

កុមារដ្ឋាន

**នព្វន្ត**

ចំនួនពី ៣០ ដល់ ៥០

*លេខបូកនិងលេខសង លេខគុណ ខ្ទង់ ឥតត្រាទុក*

*មតិសំខ្យា : បន្ថែមនឹងបន្ថយម្ដងៗ ៣*

*មតិសំខ្យា.—* មុននឹងចាប់បង្រៀនពន្ធ គ្រូត្រូវបង្រៀនសិស្ស ឱ្យគិតនឹងរាប់លេខ ដោយមតិសំខ្យាសិន (គិតនឹកទទេ ឥតសរសេរ) ។ វិធីនេះមានកំនួនពេល ត្រឹមតែ ៥ មីនុត ។ ចំនួនដែលត្រូវឱ្យរាប់ គឺចំនួន ដែលសិស្សបានរៀនរួចហើយ ។

*ឧទាហរណ៍* = ឱ្យសិស្សរាប់ ពី ១ ដល់ ៣០ ហើយ ពី ៣០ ចុះមក ១ វិញ បន្ថែមឬបន្ថយម្ដងៗ ៣

*១)— រាប់ពី ១ ដល់ ៣០ បន្ថែមម្ដង ៣*

*៤ ; ៧ ; ១០ ; ១៣ ; ១៦ ; ១៩ ; ២២ ; ២៥ ; ២៨ ;*

*២)— រាប់ពី ៣០ ចុះមក ១, បន្ថយម្ដង ៣*

*២៧ ; ២៤ ; ២១ ; ១៨ ; ១៥ ; ១២ ; ៩ ; ៦ ; ៣ ; ០ ;*

*មេរៀន.—* បង្រៀនឱ្យរាប់, មើល, សរសេរលេខនឹងចំនួនពី ៣០ ដល់ ៥០:




៣២= សាមសិបពីរ

៤៦= សែសិបប្រាំមួយ

លេខ៣២.– គ្រូលើកបង្កើះ ៣ បាច់ (១ បាច់បង្កើះ ១០) ហើយ សួរសិស្ស តើមានបង្កើះដប់ប៉ុន្មានដង ? ។ រួចហើយ បង្ហាញបង្កើះពីរវាយទៀត ។ រួចគ្រូប្រាប់សិស្សថា៖

*ដប់បីដងនិងពីរវាយត្រូវជាសាមសិបពីរ (៣២) ។*

គ្រូសរសេរលេខ ៣២ នៅលើក្ដារខៀនឲ្យសិស្សមើល សរសេរនៅលើក្ដារឆ្នួនរៀងខ្លួន ។

| | |
|---|---|
| ៣០ និង ១ សាមសិបមួយ ៣១ | ៤០ និង ១ សែសិបមួយ ៤១ |
| ៣០ និង២ –"– ពីរ ៣២ | ៤០ និង២ សែសិបពីរ ៤២ |
| ៣០ និង៣ –"– បី ៣៣ | ............... |
| ៣០ និង៤ –"– បួន ៣៤ | ............... |
| ៣០ និង៥ –"– ប្រាំ ៣៥ | ............... |
| ៣០ និង៦ –"– ប្រាំមួយ ៣៦ | ............... |
| ៣០ និង៧ –"– ប្រាំពីរ ៣៧ | ............... |
| ៣០ និង៨ –"– ប្រាំបី ៣៨ | ............... |
| ៣០ និង៩ –"– ប្រាំបួន ៣៩ | ............... |
| ៣០ និង១០ –"– សែសិប ៤០ | ៤០ និង ១០ ហាសិប ៥០ |

(លេខនិមួយខាងលើនេះ ត្រូវបង្រៀនដូចគ្នានឹងលេខ ៣២ បង្ហាញខាងលើស្រាប់) ។

*វិធីហាត់គិតមាត់ទទេ.—* ឲ្យសិស្សមើលបំនួនខាងក្រោមនេះ ។

៣៣ ; ៤៦ ; ៥០ ; ៤៩ ; ៣៥ ; ៤២ ។

ឲ្យសិស្សរាប់ ពី ៥០ ថយមកដល់ ៣០ ។ ពី ៤០ ថយមកដល់ ២៥ ។ ពី ៤៧ ថយមកដល់ ២៧ ។

*វិធីហាត់គិតមាត់ទទេ និងហាត់សរសេរ.—*

១ – ឲ្យសិស្សមើលបំនួនគត់គូ ពី ២៨ ដល់ ៤៨ ។

២– ឲ្យសិស្សមើលបំនួនសេស ពី ២៩ ដល់ ៤៩ ។

៣– ឲ្យសិស្សសរសេរជាលេខ បំនួនទាំងអស់នេះ សែសិបមួយ, សាមសិបបួន, សាមសិប, សែសិបប្រាំពីរ, ។

*លេខបូកនិងលេខសងដែលមានលេខពីរខ្ទង់ឥតត្រាទុក*

*លេខបូក.—* ខ្ញុំចង់បូក ២២ សេន និង ១៦ សេន ខ្ញុំសរសេរលេខទាំងពីរខាងលើនេះ មួយលើមួយក្រោម គឺលេខ

២២ ខ្ទង់រាយនៅក្រោមខ្ទង់រាយ លេខខ្ទង់ដប់នៅក្រោម
\+ ១៦ ខ្ទង់ដប់ ។ ខ្ញុំគូសបន្ទាត់មួយ ហើយខ្ញុំបូកលេខចាប់
៣៨ ពីខ្ទង់រាយ ពីលើមកក្រោម ។ ខ្ញុំថា = ២ នឹង ៦
ត្រូវជា ៨; ខ្ញុំសរសេរលេខ ៨ នៅក្រោមខ្ទង់រាយ ។
២ នឹង ១ ត្រូវជា ៣ ខ្ញុំសរសេរលេខ ៣ នៅក្រោម
ខ្ទង់ដប់ ។

*លេខដក*.— ខ្ញុំមានបង្កើះនៅដៃ ៣៧ ។ ខ្ញុំដាក់ ២៥ ទៅលើតុ ។
ខ្ញុំចង់ដឹង តើនៅសល់បង្កើះប៉ុន្មាននៅដៃខ្ញុំ ។
៣៧ ខ្ញុំចង់ដក ឬហូត ២៥ ពី ៣៧ ។
\− ២៥ ខ្ញុំសរសេរលេខលើក្រោមគ្នា ដូចជាខ្ញុំសរសេរលេខ
១២ បូកដែរ ។ ខ្ញុំហៅលេខពីក្រោមទៅលើ ចាប់ពីខ្ទង់
រាយ ខ្ញុំថា ៥ យកទៅសង ៧ នៅសល់ ២ ។
ខ្ញុំសរសេរលេខ ២ ក្រោមខ្ទង់រាយ ។ ២ យកទៅ
សង ៣ នៅសល់ ១ ។ ខ្ញុំសរសេរលេខ ១ នៅ
ក្រោមខ្ទង់ដប់ ។

*វិធីហាត់គិតមាត់ទទេ និងហាត់សរសេរ.*

សូមគ្រូជ្រើសរើស លេខបូកនឹងលេខសងដាក់ឲ្យសិស្សធ្វើឲ្យបានច្រើន ឲ្យយល់ច្បាស់ –

១៨ + ១១ = : ១៧ + ១២ = ;

១៥ + ១២ = ; ១៦ + ១៣ = ;

២៨ – ១២ = ; ៣៧ – ១៥ = ;

២២ – ១២ = ; ៣៦ – ១៤ = ;

២៥ – ២២ = ;

---

កុមារដ្ឋាន

## រង្វាស់រង្វាល់

### រង្វាល់ លីត្រ

*(លីត្រ គ្រប់ បែប)*

លីត្រ សំរាប់វាល់បំណុះ ឬគ្រាប់សារពើទាំងឡាយ ។ លីត្រ មានច្រើនយ៉ាង មានលីត្រ សំណប៉ាហាំង លីត្រស៊ុីរឡាតសំរាប់វាល់វត្ថុរាវ លីត្រ ឈើសំរាប់វាល់គ្រាប់ លីត្រដិបក៍មានដែរ ។

ក)- វិធីពិនិត្យរង្វាស់ (លីត្រជប)

១)- គ្រូលើករង្វាស់ លីត្រ ហើយប្រាប់សិស្សថា នេះរង្វាស់ ឈ្មោះថា៖ "លីត្រ" ។

២)- គ្រូសរសេរ ឈ្មោះរង្វាស់នោះលើក្ដារខៀនគ្រប់តួអក្សរ "លីត្រ" នឹងកាត់ "ល" ។

៣)- គ្រូឱ្យសិស្សសរសេរហើយឱ្យមើល ។

៤)- គ្រូឱ្យសិស្សពិនិត្យរង្វាស់នោះ (កំពស់,រាង,កែវ, កំរិត) ។

៥)- គ្រូចាក់ទឹកពណ៌ក្រហម ដើម្បីឱ្យសិស្សមើលច្បាស់ពីចំណុះ១លីត្រ ទៅក្នុងជប ហើយចាក់ទឹកនោះទៅក្នុងរង្វាស់លីត្រ សុីឡាតទៀត។ ទើបគ្រូប្រាប់សិស្សថា នេះទឹកចំណុះ១លីត្រ ។

៦)- គ្រូសួរបញ្ជាក់ទៅសិស្សឱ្យរករង្វាស់អ្វីខ្លះ ដែលមានចំណុះ១លីត្រ ឬប្រហែល១លីត្រ ។

(ខ)- វិធីហាត់ស្ទាបចំណុះ គ្មានប្រើរង្វាស់ លីត្រនិងវិធីបង្រៀនសិស្សឱ្យចេះកាល់ឱ្យត្រឹមត្រូវ ។

១)- គ្រូលើកឧបមាដូចជាធុងទឹក ១ធំ ឲ្យសិស្សមើល ហើយបង្គាប់ឲ្យសិស្សស្មានបំណុះធុងទឹកនោះតើ មានប៉ុន្មានលីត្រ ? សិស្សត្រូវកត់ត្រាពាក្យឆ្លើយ នៅលើក្ដារឆ្នួនរៀងខ្លួន ។

២)- គ្រូបង្គាប់ឲ្យលើកក្ដារឆ្នួន ហើយត្រួតត្រាមើល បើមានសិស្សណាមួយ ឆ្លើយខុសឆ្ងាយពេក ពីបំណុះធុងនោះ ៗ គ្រូហៅសិស្សនោះមកកាន់យកលីត្រវាល់ទឹកចាក់ទៅក្នុងធុងនោះ ។

៣)- គ្រូបង្ហាញធុងឬប៉ោតផ្សេង ៗ ដទៃទៀតឲ្យសិស្សស្មានបំណុះ ដូចជាស្មានបំណុះធុងទឹកដែរ ។

(គ)- *វិធីហាត់សរសេរ*.- គ្រូចោទចំណោទមួយ ឲ្យសិស្សប្រុងស្ដាប់ ហើយឲ្យសិស្សគិត ដោយមតិសំឡា រួចកត់ត្រាទុកនៅលើក្ដារឆ្នួនរៀងខ្លួន ដូចជាឧទាហរណ៍ខាងក្រោមនេះ:

ខ្ញុំមានប្រេងកាតចំនួន ១៨ លីត្រ ។ ខ្ញុំបានយកប្រើអស់ចំនួន ៦ លីត្រ ។ សួរថា តើនៅសល់

ប្រែងកាតប៉ុន្មានលើត្រះទៀត ? ។ (បំណោទនេះគ្រះហោទមាត់ទទេ កត់ត្រាលើក្ដារខៀនតែលេខបានហើយ) ។

## លោកនីតិ

សំរាប់គ្រប់ថ្នាក់ សុំជ្រើសរើស តម្រូវតាមរបៀបការសិក្សានូវថ្នាក់នីមួយៗ ផងចុះ សេចក្ដីអធិប្បាយខាងក្រោមនេះ គឺជាគោលអាចឲ្យគ្រូធ្វើជាគំរូឲ្យងាយនឹងតែងអំពីកិច្ចបញ្ញត្តិអ្វីផ្សេងៗ តាមរបៀបសិក្សារាល់ខែ ។

### ១– អំពីច្បាប់

សេចក្ដីអធិប្បាយ.– ច្បាប់គឺសេចក្ដីបញ្ញត្តិពីរាជការ សំរាប់ឲ្យអ្នកប្រទេសទាំងមូលប្រតិបត្តិតាម ។ ច្បាប់សំរាប់ប្រទេសមានពីរយ៉ាង គឺច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ។ ច្បាប់ព្រហ្មទណ្ឌគឺច្បាប់ដែលតុលាការសំរាប់ពិភាក្សាផ្ដន្ទាទោសក្ដី ពិន័យក្ដី ឲ្យមនុស្សដែលប្រព្រឹត្តខុសឬល្មើសនឹងបញ្ញត្តិ សំរាប់ប្រទេសឲ្យរាងចាលដើម្បីឲ្យគាត់កិរិយាត្រឹមត្រូវ ដូចហាមថាកុំឲ្យជេរប្រមាទគេ កុំលួច

ឬធ្វើបាបគេ កុំឲ្យបាបធ្វើឲ្យគេវិនាស ក្រមច្បាប់នេះដែលសម្រាប់កម្ពុជរដ្ឋហៅថា " ក្រមព្រហ្មទណ្ឌខេមរៈ "

រដ្ឋប្បវេណី គឺច្បាប់បញ្ញត្តិ អំពីដំណើរកិច្ចការនិងសណ្ដាប់ធ្នាប់ របៀបរបបផ្សេង ៗ តាមបវេណីរបស់ប្រជាជនក្នុងប្រទេស ដែលនៅក្នុងឱវាទនៃរាជការបញ្ញត្តិ ដូចទាស់ទែងគ្នា អំពីទ្រព្យមត៌ក អំពីដីស្រែចំការផ្សេង ៗ ។

---

ពាក្យចោទ.— យ៉ាងដូចម្ដេចដែលហៅថាច្បាប់ ។ យ៉ាងដូចម្ដេចដែលហៅវិន័យក្រិត្យក្រម ។ (វិន័យនឹងក្រិត្យក្រម គឺក្បួនទូន្មានប្រដៅឲ្យប្រព្រឹត្តល្អ) ច្បាប់សម្រាប់ជនក្នុងប្រទេសយើងមានប៉ុន្មានយ៉ាង ។ ច្បាប់ព្រហ្មទណ្ឌសម្រាប់ផ្ដន្ទាទោសយ៉ាងណាខ្លះ ។ល។

*មេរៀនសង្ខេប.*— ច្បាប់គឺកិច្ចបញ្ញត្តិ ពីរាជការផែនដីសម្រាប់ប្រើទៅលើជនទាំងអស់ក្នុងប្រទេស។ច្បាប់ព្រហ្មទណ្ឌ សម្រាប់ពិភាក្សាកាត់ទោសឬវិន័យជនណា ដែលប្រព្រឹត្តល្មើសខុសនឹងមាត្រាណាមួយ ដែលមានសម្ដែងក្នុងក្រមព្រហ្មទណ្ឌខេមរៈ ។ ច្បាប់រដ្ឋប្បវេណី បញ្ញត្តិ អំពីដំណើរកិច្ចការនិងសណ្ដាប់របៀបរបបផ្សេង ៗ តាមបវេណីរបស់ប្រជាជនក្នុងប្រទេស ដែលនៅក្នុងឱវាទនៃរាជការបញ្ញត្តិ ។

## អំពីអំណាច

អំណាចគឺដំណើរអាចធ្វើអ្វី ៗ បានតាមលំអានច្បាប់ ។ អំណាចគ្រប់យ៉ាង មកពីព្រះមហាក្សត្រិយ៍ត្រូវប្រើទៅតាមបទបញ្ញត្តិ ដែលមានអធិប្បាយក្នុងរដ្ឋធម្មនុញ្ញ ។ រដ្ឋសភាជាអ្នកប្រើអំណាចនីតិបញ្ញត្តិក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។

អ្នកដែលមានសិទ្ធិផ្ដើមគំនិតតែងច្បាប់នោះ គឺព្រះមហាក្សត្រិយ៍ គណៈរដ្ឋមន្ត្រី សមាជិកនៃរដ្ឋសភា និងសមាជិកនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ ។

គណៈរដ្ឋមន្ត្រីជាអ្នក ប្រើអំណាចនីតិប្រតិបត្តិ ក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។

សាលកជំរះក្ដីគ្រប់ជាន់គ្រប់ប៉ែក ជាអ្នកប្រើអំណាចតុលាការ ក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។

---

ពាក្យសួរដោយ.— យ៉ាងដូចម្ដេចដែលហៅថាអំណាច ។ អំណាចប្រើបានតាមចិត្តឬទេ ។ អំណាចគ្រប់យ៉ាងមកពីណាមក ។ គ្រូបង្រៀនមានអំណាចឬទេ ។ លើអ្នកណា ។ (មានអំណាចលើសិស្ស) ។ អ្នកណាដែលមានអំណាច ផ្ដើមគំនិតតែងច្បាប់ ។ អ្នកណាដែលមានអំណាចបញ្ញត្តិ ។ល។

## អំពីទោស

នៅគ្រប់ប្រទេសក្នុងលោក មានច្បាប់បញ្ញត្តិដល់ប្រជាជនឲ្យប្រព្រឹត្តសុចរិតត្រឹមត្រូវ បើជនណាប្រព្រឹត្តល្មើសខុសនឹងបទបញ្ញត្តិណាមួយនោះ រាជការនឹងពិន័យឬធ្វើទោសតាមកំហុសឲ្យរាងចាល

ឯទោសសំរាប់ផ្តន្ទាបណ្តាជនមានបីយ៉ាងគឺ លហុទោស មជ្ឈិមទោស ឧក្រិដ្ឋទោស ។

លហុទោស គឺទោសស្រាលសំរាប់ធ្វើទោសផ្តាល តាមដំណើរប្រព្រឹត្តខុសឬពិន័យជនណា ដែលល្មើសនឹងច្បាប់បញ្ញត្តិដូចឈ្លោះប្រកែកជេរគ្នា, សង់ឬដួសដល់គេបាដ្ឋាន ឬលេងភ្លេងមិនសុំច្បាប់រាជការជាមុន ។

មជ្ឈិមទោស (ទោសយ៉ាងកណ្តាលមធ្យម) សំរាប់ដាក់ទណ្ឌកម្ម លើជនណាដែលមានកំហុស លើសពីលហុទោសឡើងទៅ ដូចលួចទ្រព្យគេ ព្យាបាទគេឲ្យវិនាស ឬឲ្យមានរបួសធ្វើការពុំបានមានកំណត់ថ្ងៃ ។

ឧក្រិដ្ឋទោស (ទោសយ៉ាងធ្ងន់) សំរាប់ផ្តន្ទាជនណាដែលប្រព្រឹត្ត ខុសធ្ងន់លើសពីមជ្ឈិមទោសឡើងទៅ ដូចប្លន់យកទ្រព្យ

គេមានគ្រឿង សស្ត្រាវុធកាន់នៅដៃកាប់សម្លាប់គេ ឬបំពុលគេឲ្យស្លាប់ដោយថ្នាំពុលផ្សេងៗ ឬកំហែងជាប់ចង់ស្ត្រីដែលពុំទាន់គ្រប់ការ ។ល។

---

សួរថា ៖ — មនុស្សយើងត្រូវប្រព្រឹត្តយ៉ាងណាទើបបានប្រសើរ ។ បើប្រព្រឹត្តខុសនឹងមានទោសឬទេ ។ ទោសសំរាប់ផ្ដន្ទាបណ្ដាជនមានប៉ុន្មានយ៉ាង ។ ទោសណាខ្លះ ។ បើឆបោកទ្រព្យគេត្រូវយកទោសណាមកផ្ដន្ទា ។ បើលួចអុចផ្ទះគេត្រូវយកទោសណាមកផ្ដាល ។ (ឧក្រិដ្ឋទោស) ។ល។

## អំពីសំបុត្រកំណើត

សំបុត្រកំណើតមានប្រយោជន៍ណាស់ ហេតុនេះត្រូវកុំធ្វេសប្រហែសឲ្យសោះ បើមានកូនកើតក្នុងរវាងបីថ្ងៃត្រូវរកសាក្សីបានពីរនាក់ ហើយនាំគ្នាទៅសាលាឃុំ ប្ដឹងសុំបុះកំណើតកុមារនោះ ហើយត្រូវសុំចម្លងកំណើតមួយច្បាប់ទុកប្រើការទៅថ្ងៃក្រោយ ដូចជាចូលទៅរៀនក្នុងសាលា ឬបង់ពន្ធ ឬប្រួស ឬទាស់ទែងគ្នាដល់តុលាការអំពីសម្បាប់មរតកក៏ត្រូវមានជាតិសញ្ញាប័ត្រដ៏រាប ។

បើនៅក្រុងភ្នំពេញ កាលណាមានកូនកើតត្រូវទៅប្ដឹងមេសង្កាត់ (មេឃុំ) ក្នុងពេលដែលកើតនោះទើបមេឃុំចេញសំបុត្រមួយឲ្យគាត់យកទៅមន្ទីរពេទ្យបាលរោគ ដើម្បីឲ្យរាជការការពាររោគ

ទៅបណ្តុះអុតកុមារនោះភ្លាម រួចបាននាំគ្នាទៅបុះកំណើតនៅសាលាឃុំវិញក្នុងកំណត់បីថ្ងៃ ។

---

ពាក្យសួរបោទ — បើមានកូនកើតត្រូវធ្វើដូចម្ដេច ។ នៅភ្នំពេញគេធ្វើដូចម្ដេចទៀត ។ បើមិនបានទៅប្ដឹងមេឃុំឲ្យបុះកំណើតទេនោះនឹងមានទោសដូចម្ដេច ។(លក់ពិន័យ) ។ សំបុត្រកំណើតមានប្រយោជន៍យ៉ាងដូចម្ដេចខ្លះ ។

## សំបុត្រអាពាហ៍ពិពាហ៍(អាវាហវិវាហ)

មុននឹងរៀបការ កូនប្រុសស្រី ត្រូវមាតាបិតាខាងកូនស្រីទៅប្ដឹងមេឃុំចំនួន ៨ ថ្ងៃមុនរៀបម៉ង្គលនេះ មេឃុំត្រូវបេញសំបុត្រមួយប្លាប់ មានបុះឈ្មោះសាមីខ្លួនប្រុសស្រីហើយបញ្ញត្តិថាបើឈ្មោះណាមានទាក់ទងនឹងនាងនេះនឹងអ្នកនេះត្រូវប្ដឹងតវ៉ាក្នុងរវាង ៨ ថ្ងៃមុននឹងរៀបអាវាហវិវាហ តែបើហួសកំណត់ថ្ងៃនេះហើយនឹងទុកជាស្រេច លះរៀបអាពាហ៍ពិពាហ៍ស្រេចហើយ មាតាបិតានឹងកូនប្រុសស្រីមានសាក្សីពីរនាក់ នាំគ្នាទៅបុះអេតាសុីវិលនៅសាលាឃុំ រួចសុំសំណៅមួយសន្លឹកទុកប្រើការទៅពេលក្រោយ ពីព្រោះមានច្បាប់បញ្ញត្តិថាជនណាយកគ្នាជាប្ដីប្រពន្ធ ពុំបានបុះអេតាសុីវិលនោះ មិន

ពេញជាប្ដីប្រពន្ធទេ បើមានហេតុ ទាស់ទែងលែងលះគ្នានោះរាជការមិនទទួលបណ្ដឹងឡើយ បដិសេធចោលជាអសារឥតការ ។

---

សួរចោទ.— សុំសួរចោទនាំសិស្សនិយាយឲ្យបានចេះប្រាកដ ដូចមានរបៀបមុន ៗ ស្រាប់ ។

## មរណភាព

របៀបកើតនឹងស្លាប់មិនប្លែកគ្នាប៉ុន្មានទេ នៅទីក្រុងបើមានមនុស្សស្លាប់គេទៅប្ដឹងសុំសំបុត្រមេឃុំ រួចយកសំបុត្រនោះទៅមន្ទីរការពាររោគ ដើម្បីឲ្យគ្រូពេទ្យទៅពិនិត្យមើលខ្មោចនោះ តើស្លាប់ដោយរោគអ្វី ។ លុះពេទ្យពិនិត្យមើលត្រឹមត្រូវហើយ ទើបអនុញ្ញាតឲ្យយកខ្មោចនោះទៅកប់ឬបូជាតាមកំណត់ពេលវេលាដែលគ្រូពេទ្យបានបញ្ជាក់ក្នុងសំបុត្រនោះស្រាប់ ។ រួចពីនោះមកបីថ្ងៃទើបបានគេនាំគ្នាទៅចុះមរណភាពឯសាលាឃុំដូចជាចុះកំណើតនោះដែរ ។

## សេចក្ដីអធិប្បាយរដ្ឋធម្មនុញ្ញ

### សេរីភាព សិទ្ធិ និងករណីយកិច្ចរបស់ខេមរជន

ដូចមានពោលមកហើយ បុគ្គលរាប់សែនរាប់លាននាក់រួមគ្នាតាំងឡើងជារដ្ឋ ។ រដ្ឋ (ឬរាជការ) មានអំណាចបង្គាប់បញ្ជា

ផ្តន្ទាទោសលើបុគ្គលនិមួយៗ (ឬរាស្ត្រ) ។ អំណាចនេះធំខ្លាំងណាស់ ធំលើសម្បត្តិទ្រព្យរាងកាយ រហូតដល់អាយុជីវិតនៃបុគ្គលនិមួយៗ ។ ទាំងនេះក៏ព្រោះជាប្រយោជន៍ដល់បុគ្គលទាំងអស់គ្នា ដូចជាការចាប់ចោរដាក់គុក រឹបជាន់សម្បត្តិទ្រព្យ ប្រហារជីវិតមនុស្សក្បត់ជាតិជាដើម ។ តែរដ្ឋអាចប្រើអំណាចរំលោភលើបុគ្គលនិមួយៗ ដូចយើងធ្លាប់បានឃើញមកហើយ ។ ហេតុនេះទើបរដ្ឋធម្មនុញ្ញបញ្ញត្តិកុំឲ្យរដ្ឋប្រើអំណាចជ្រុលហួសទៅលើបុគ្គលបាន ។

ក្នុងបំពូកនេះនិងក្នុងបំពូក ៣ ត្រង់មាត្រា ១៧ និង ១៨ មានស្រដីអំពីសេរីភាព (libertés) និងសមភាព (égalité) របស់ខេមរជន គោលសេរីភាពនឹងគោលសមភាព (les principes de liberté et d'égalité) ជាមូលដ្ឋាន (base) នៃសិទ្ធិរបស់បុគ្គល (droits individuels) សិទ្ធិរបស់បុគ្គលនេះ រដ្ឋមិនត្រូវល្មើសបានឡើយ ។

ក្នុងបំពូកនេះ មានស្រដីអំពីករណីយកិច្ចរបស់ខេមរជនផង ព្រោះកាលមានសិទ្ធិក៏ត្រូវមានករណីយកិច្ចជាគូគ្នា ។

មាត្រា ៣.– សេរីភាពជាដំណើរអាចធ្វើអ្វីបានគ្រប់យ៉ាង កុំឲ្យតែប៉ះពាល់ឲ្យខូចសិទ្ធិអ្នកដទៃ ។ លក្ខណៈនៃការប្រើសេរីភាពមានត្រាទុកក្នុងច្បាប់ ។

អ្វីដែលច្បាប់មិនបង្គាប់ឲ្យធ្វើទេ ជនណាក៏ដោយមិនអាចត្រូវគេបង្ខំឲ្យធ្វើបានឡើយ ។

សេចក្ដីអធិប្បាយ.— មានសេរីភាព គឺធ្វើអ្វីក៏បាន តែក៏មិនបេះតែបានជំរាបទៅទេ ត្រូវមានកំណត់ដែរ ។ ឧបមាដូចជាខ្ញុំចង់ស្រែកច្រៀង ខ្ញុំមានសេរីភាពស្រែកច្រៀងដូចម្ដេចក៏បាន ។ ប៉ុន្តែបើដល់ពេលយប់ជ្រៅ ខ្ញុំស្រែកច្រៀងខ្លាំងៗទៅ អ្នករកសំរាន្តពុំលក់ ។ អ្នកមានសិទ្ធិសំរាន្តពេលយប់ បើខ្ញុំច្រៀងមិនឲ្យអ្នកសំរាន្តបាន នោះគឺខ្ញុំធ្វើឲ្យខូចសិទ្ធិរបស់អ្នកខាងការសំរាន្តសំរាក-កាយ ។ ក្នុងករណីដូច្នេះ (dans ce cas) សេរីភាពរបស់ខ្ញុំអស់តែត្រឹមនេះ ។ នេះហើយជាព្រំដែននៃសេរីភាព ។

"លក្ខណៈនៃការប្រើសេរីភាពមានត្រាទុកក្នុងច្បាប់" ប្រែសេចក្ដីថា ការប្រើសេរីភាពទៅដោយវិធីណា តាមបែបណាខ្លះនោះមានបញ្ញត្តទុកក្នុងច្បាប់ ។ ដូចជាសេរីភាពខាងការធ្វើកាសែត, ដើម្បីនឹងប្រើសេរីភាពនេះបាន ត្រូវឲ្យមានអ្នកចាត់ការម្នាក់ជាអ្នកទទួលខុសត្រូវ, អ្នកចាត់ការនោះត្រូវធ្វើពាក្យទៅជំរាបអ្នករាជការមុខក្រ-សួង ។ល។ នេះហើយហៅថាលក្ខណៈនៃការប្រើសេរីភាពខាង

ការធ្វើកាសែត ។ លក្ខណៈទាំងនេះ មានត្រាទុកក្នុងច្បាប់ ។ បើច្បាប់នេះមិនទាន់មាន ក៏ត្រូវតាំងឲ្យមានឡើង ។

វគ្គទី ២ នៃមាត្រា ៣ នេះ មានសេចក្ដីថា ៖ "អ្វីដែលច្បាប់មិនបង្គាប់ឲ្យធ្វើទេ ជនណាក៏ដោយមិនអាចត្រូវគេបង្ខំឲ្យធ្វើបានឡើយ" សេចក្ដីនេះក៏ក្បោះក្បាយល្មមស្ដាប់បានហើយ តែដើម្បីឲ្យច្បាស់លាស់ឡើងទៀត គួរយើងរកឧទាហរណ៍មួយមកបញ្ជាក់ថែមផង ។ មនុស្សដែលដើរកាត់មុខវត្តអារាម ខ្លះក៏បើកមួក ខ្លះក៏មិនបើកមួក ការបើកមួកនៅមុខវត្តនេះគ្មានច្បាប់ណាបង្គាប់ឲ្យធ្វើទេ គឺធ្វើដោយចិត្តឯង ។ ហេតុនេះ នរណានឹងបង្ខំ នរណាឲ្យបើកមួកនៅមុខវត្តពុំបានឡើយ ។

---

មាត្រា ៤ — នឹងចោទចាប់ ឬឃុំឃាំង ជនណាមួយបានលុះតែជនោះប្រព្រឹត្តបទដែលមានត្រាទុកក្នុងច្បាប់, ឯអ្នកចោទអ្នកចាប់ ឬអ្នកឃុំឃាំង ត្រូវប្រតិបត្តិតាមរបៀបដែលច្បាប់បានបញ្ញត្តិទុក ។

*សេចក្ដីនេះនាំឲ្យកើតទៅជាបញ្ហា ៥ ប្រការ*

១) បទប្រព្រឹត្តដែលមានត្រាទុកក្នុងច្បាប់នោះ ដូចម្ដេចខ្លះ?

២) នរណាជាអ្នកចោទ?

៣) នរណាមានអំណាចចាប់? ដើម្បីនឹងចាប់ត្រូវធ្វើទៅតាមរបៀបដូចម្ដេចខ្លះ ទើបត្រឹមត្រូវតាមច្បាប់?

៤) នរណាមានអំណាចឃុំឃាំង? ដើម្បីនឹងឃុំឃាំងត្រូវធ្វើទៅតាមរបៀបដូចម្ដេចខ្លះ ទើបត្រឹមត្រូវតាមច្បាប់?

៥) នរណាចាប់ឬឃុំឃាំងខុសពីច្បាប់ត្រូវទទួលទោសយ៉ាងណាខ្លះ?

យើងបានពិនិត្យច្បាប់ដែលមានប្រើសព្វថ្ងៃនេះ ហើយបានប្រឹក្សានឹងអ្នកប្រឹក្សាការក្នុងមុខក្រសួងតុលាការ ដោយចង់ដឹងថាច្បាប់ដែលមានប្រើសព្វថ្ងៃ ឲ្យសេចក្ដីឃុំគ្រងរក្សាដល់សេរីភាពខាងរាងកាយនៃខេមរជនប៉ុណ្ណាទៅ ។ ទាំងនេះក៏ព្រោះយើងមានបំណងឲ្យបងប្អូនទាំងឡាយ ចេះប្រើបញ្ញត្តិច្បាប់ជាអាវុធការពារខ្លួន ឲ្យរួចពីការសង្កត់សង្កិនធ្វើបាប ដើម្បីឲ្យបានគ្រងជីវិតដោយថ្លៃថ្នូរសមល្មមនឹងឋានៈជាមនុស្សតទៅ ។ ដើម្បីឲ្យសាមញ្ញជនយល់បានដោយច្បាស់លាស់ នោះត្រូវពន្យល់ដល់ខ្មែរបណ្ឌិតណាស់ ។

យើងនឹងពន្យល់ឲ្យល្អិតដល់ម្ល៉ោះក្នុងទីនេះពុំបានទេ ព្រោះនឹងនាំឲ្យសេចក្ដីអធិប្បាយវែងពេក ។ យើងនឹងព្យាយាមសង្ខេបយ៉ាងបំផុត តែក៏គង់នៅវែងមិនតិចដែរ ។

ប្រការ ១–បទប្រព្រឹត្តដែលមានត្រាទុកក្នុងច្បាប់នោះដូចម្ដេចខ្លះ?

បទប្រព្រឹត្តទាំងនោះ ជាបទល្មើសដែលគេតែងបែកជាបីសណ្ឋាន គឺបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ស្រេចតែទោសដែលត្រូវផ្ដន្ទាជាទោសឧក្រិដ្ឋ (ធ្ងន់) មជ្ឈិម (កណ្ដាល) ឬលហុ (ស្រាល) ។

បទឧក្រិដ្ឋជាបទល្មើសដែលត្រូវផ្ដន្ទាទោស ៖

– ប្រហារជីវិត (ថ្នាក់ទី ៣)

– ដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់អស់មួយជីវិត (ថ្នាក់ទី ២)

– ឬដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់មានកំណត់វេលា (ថ្នាក់ទី ១)

(មាត្រា ២១ ក្រមព្រហ្មទណ្ឌ)

បទមជ្ឈិមជាបទល្មើសដែលត្រូវផ្ដន្ទាទោស ៖

– ដាក់គុកពី ១ ឆ្នាំទៅដល់ ៥ ឆ្នាំ ហើយពិន័យពី ១០០ រៀលទៅដល់ ១០០០ រៀល (ថ្នាក់ទី ៣) ។

– ដាក់គុកពី ១ ខែទៅដល់ ១ ឆ្នាំ នឹងពិន័យពី ៣០ រៀល ទៅដល់ ១០០ រៀល (ថ្នាក់ទី ២)។ ឬ

– ដាក់គុកពី ៦ ថ្ងៃទៅដល់ ១ ខែ នឹងពិន័យពី ៦ រៀលទៅដល់ ៣០ រៀល (ថ្នាក់ទី ១) ។

ទោសមជ្ឈិមទាំង ៣ ថ្នាក់នេះ គ្រាន់តែដាក់គុក ឬគ្រាន់តែពិន័យក៏បាន (មាត្រា ២២ ក.ព.) ។

បទលហុជាបទល្មើសដែលត្រូវផ្ដន្ទាទោសដាក់គុកពី ១ ថ្ងៃទៅដល់ ៥ ថ្ងៃ នឹងពិន័យពី ៤០ សេនទៅដល់ ៥ រៀល ឬគ្រាន់តែដាក់គុក ឬគ្រាន់តែពិន័យក៏បាន (មាត្រា ២៣ ក.ព.) ។

បើជនណាមិនបានប្រព្រឹត្តបទល្មើសដែលមានត្រាទុកក្នុងច្បាប់នេះទេ គ្មាននរណាអាចចោទចាប់ ឬឃុំឃាំងជននោះបានឡើយ ។ ជនណាចោទចាប់ ឬឃុំឃាំងមនុស្សដែលពុំបានប្រព្រឹត្តបទដែលមានត្រាទុកក្នុងច្បាប់ ជននោះធ្វើខុសនឹងច្បាប់ ហើយត្រូវទទួលទោសលើខ្លួន ដូចនឹងមានពណ៌នាទៅខាងក្រោយនេះ ។

## ប្រការ ២ – នរណាជាអ្នកចោទ ?

តាមធម្មតា កាលមានបទល្មើសជាបទឧក្រិដ្ឋឬមជ្ឈិមបណ្ដាល

កើតឡើង អ្នករងគ្រោះឬជនឯទៀតអាចប្ដឹងជាបទអាជ្ញាបាន ។ តែដែលនឹងចោទប្រកាន់ ឲ្យប្រើអំណាចច្បាប់ដាក់ទណ្ឌកម្មនោះ មានតែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬអ្នកតំណាងរដ្ឋមន្ត្រីនេះទើបចោទបាន ។ ក្នុងជាន់ដំបូងអ្នកតំណាងនោះ គឺព្រះរាជអាជ្ញា ។ ជំនុំជម្រះក្នុងក្ដីអាជ្ញាអ្នកដើមចោទ គឺព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ពុំមែនអ្នកដើមបណ្ដឹងទេ ។ ក្នុងសាលាដំបូងណា ដែលគ្មានព្រះរាជអាជ្ញា ចៅហ្វាយសាលាដំបូងនោះទទួលមុខការជួស ។

(មាត្រា ៨ នឹង ៦៩ ក្រមពិភាក្សាព្រហ្មទណ្ឌ)

ពាក្យប្ដឹងក្នុងក្ដីអាជ្ញា នឹងជូនផ្ទាល់ទៅព្រះរាជអាជ្ញាតែម្ដងក៏បាន នឹងជូនទៅនាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ណាមួយក៏បាន (Officier de police judiciaire) (មាត្រា ៤៥ នឹង ៧៣ ក.ព.ព.) ឬនឹងជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏បាន (មាត្រា ៨ ក.ព.ព.) ។

នាម៉ឺនដែលហៅថានាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌នោះគឺ ៖

– ចៅហ្វាយខេត្ត នឹងចៅហ្វាយស្រុក ;
– មេឃុំឬជំទប់ បើឥតពីមេឃុំ ;

– គុម្មីស្មៀរប៉ូលិស ;

– នាយសង់ដារម ( Officiers de gendarmerie ): មេកងសង់ដារម ( chef de brigade ) និងសង់ដារម, សៃហ្វប៉ុស្តសង់ដារម ;

– មេព្រះនគរបាលសំងាត់ និងភ្នាក់ងារដែលស្ដីទីកុម្មីស្មៀរប៉ូលិស ;

– សៃហ្វប៉ុស្តរដ្ឋបាល និងសៃហ្វប៉ុស្តប្រទល់ដែន ;

– ចៅក្រមសាលាលហុ ;

– ព្រះរាជអាជ្ញា ;

– សុភាបារបុរស ។ (មាត្រា ៤០ ក.ព.ព.)

នាម៉ឺនណាបានទទួលបណ្ដឹងហើយ មិនបញ្ជូនទៅតុលាការមុខក្រសួង នាម៉ឺននោះអាចត្រូវទោសមជ្ឈិមថ្នាក់ទី ២ (មាត្រា ២៤៤ ក.ព.) ។ បើនាម៉ឺននោះបំបិទបំបាំង ឬមានបំណងនឹងបំបិទបំបាំងបទល្មើសុខក្រិដ្ឋឬមជ្ឈិមដែលខ្លួនបានដឹងហើយ ឬមួយបំបាត់ឬមានបំណងនឹងបំបាត់ភស្តុតាងបទល្មើសនោះ នោះអាចត្រូវទោសមជ្ឈិមថ្នាក់ទី ៣ (មាត្រា ២៤៥ ក.ព.) ។

បើព្រះរាជអាជ្ញាមិនព្រមចោទ ព្រោះយល់ថារឿងក្នុងពាក្យប្ដឹងមិនចូលជាបទល្មើសនោះ ព្រះរាជអាជ្ញាត្រូវចេញដីកាប្រាប់ទៅសាមីខ្លួនឲ្យដឹងផង (មាត្រា ៧៦ ក.ព.ព.) ។ សាមីខ្លួនអាចប្ដឹងដល់សាលាក្រុមចោទមួយលើកទៀតបាន (មាត្រា ៤៩៧ ក.ព.ព.) បើសាលាក្រុមចោទចេញសាលក្រមលើកពាក្យប្ដឹងចោលទៀត សាមីខ្លួនអាចឧទ្ធរណ៍ទៅសាលាវិនិច្ឆ័យជាទីបំផុត (មាត្រា ៥០០ ក.ព.ព.)

បើព្រះរាជអាជ្ញាយល់ឃើញថា រឿងក្នុងពាក្យប្ដឹងនោះចូលជាបទមជ្ឈិម ហើយក្នុងរឿងនោះពិបាករកសេចក្ដីពិតក្ដី អ្នកត្រូវចោទគេចខ្លួនបាត់ក្ដី ឬមួយបើព្រះរាជអាជ្ញាយល់ឃើញថារឿងក្នុងពាក្យប្ដឹងនោះចូលជាបទឧក្រិដ្ឋ នោះព្រះរាជអាជ្ញាធ្វើដីកាបាប់បញ្ជូនរឿងទៅសុភាចារបុរសឲ្យស៊ើបសួរ ។

បើព្រះរាជអាជ្ញាយល់ឃើញថា រឿងក្នុងពាក្យប្ដឹងនោះចូលជាបទមជ្ឈិម ហើយក្នុងរឿងនោះងាយរកសេចក្ដីពិត នោះព្រះរាជអាជ្ញាអាចធ្វើដីកាកោះអ្នកត្រូវចោទ ឲ្យចូលខ្លួនមកឲ្យសាលាមជ្ឈិមជំនុំជំរះតែម្ដងក៏បាន " (មាត្រា ៧៧ . ៧៩ ក.ព.ព.) ។

រឿងក្តីអាជ្ញា ច្បាប់ហាមមិនឲ្យនាម៉ឺនមុខក្រសួងផ្សះផ្សា ។ បើនាម៉ឺនមុខក្រសួងណាផ្សះផ្សា ទាល់តែរឿងនោះរលាយបាត់ទៅ មិនមានប្តឹងដល់តុលាការ នាម៉ឺននោះអាចត្រូវទោសមជ្ឈិមថ្នាក់ទី២ (តាមមាត្រា ២៤៤ ក. ព. ព.)

សេចក្តីសង្កេត.– របៀបចោទប្រកាន់ដែលពោលមកខាងលើនេះ ប្រើបានតែកាលណាអ្នកប្រព្រឹត្តបទល្មើស ជារាស្ត្រធម្មតា ។

កាលបើអ្នកប្រព្រឹត្តបទល្មើសជានាម៉ឺន ត្រូវរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សុំអនុញ្ញាតពីគណៈរដ្ឋមន្ត្រីបានជាមុនសិន ទើបព្រះរាជអាជ្ញាចោទប្រកាន់បាន (មាត្រា ១១ ក. ព. ព.) ។

បើអ្នកប្រព្រឹត្តបទល្មើសជាមេឃុំ ត្រូវឲ្យបានអនុញ្ញាតពីចៅហ្វាយខេត្តជាមុនទើបចោទប្រកាន់បាន វៀរលែងតែក្នុងបទល្មើសដែលទាន់ជាក់ស្តែង (មាត្រា ដដែល) ។

កាលបើអ្នកប្រព្រឹត្តបទល្មើសជាអ្នកតំណាងរាស្ត្រឬជាទីប្រឹក្សាព្រះរាជអាណាចក្រត្រូវបានអនុញ្ញាតពីរដ្ឋសភា ឬក្រុមប្រឹក្សាព្រះរាជអាណាចក្រជាមុន ទើបចោទប្រកាន់បាន វៀរលែងតែក្នុងបទល្មើសដែលទាន់ជាក់ស្តែង (មាត្រា ៥៥ និង ៧៧ នៃរដ្ឋធម្មនុញ្ញ) ។

បទល្មើសដែលរាប់ថា ទាន់ជាក់ស្តែងនោះ គឺបទល្មើសដែលកំពុងតែប្រព្រឹត្តរួចភាមៗ ក្នុងមួយរំពេច ឬមួយអ្នកប្រព្រឹត្តបទល្មើសនោះមានគេដេញតាមឆោឡោ ពុំនោះសោតអ្នកប្រព្រឹត្តបទល្មើសនោះ គេបានទាន់ឃើញមានភស្តុតាងនៅខ្លួនដូចជាសំលៀកបំពាក់ អាវុធគ្រឿងឧបករណ៍ ឬសំបុត្រស្នាមដែលធ្វើឲ្យសំគាល់បានថាជាអ្នកប្រព្រឹត្តបទល្មើស ឬជាអ្នកសមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើសនោះមែន តែត្រូវឲ្យទាន់ឃើញក្នុងគ្រាដែលជិតបន្ទាប់ពីពេលប្រព្រឹត្តបទល្មើសនោះ (មាត្រា ៥៤ ក. ព. ព.) ។

ប្រការ ៣– នរណាមានអំណាចចាប់ ? ដើម្បីនឹងចាប់ត្រូវធ្វើតាមរបៀបដូចម្តេចខ្លះ ទើបត្រឹមត្រូវតាមច្បាប់ ?

សេចក្តីត្រង់នេះមានករណី ២ យ៉ាង ៖

១) បទឧក្រិដ្ឋ ឬមជ្ឈិមដែលទាន់ជាក់ស្តែង

២) ក្រៅពីបទឧក្រិដ្ឋ ឬមជ្ឈិមដែលទាន់ជាក់ស្តែង ។

១.– បទឧក្រិដ្ឋ ឬមជ្ឈិមដែលទាន់ជាក់ស្តែង

ក្នុងបទឧក្រិដ្ឋ ឬមជ្ឈិមដែលទាន់ជាក់ស្តែង នរណាក៏ដោយមិនបាច់តែជានាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ទេ អាចចាប់

អ្នកប្រព្រឹត្តបទល្មើសបាន ។ ប្រសិនបើកអំណាចឲ្យឯកជនParticulier មានសិទ្ធិចាប់អ្នកប្រព្រឹត្តបទល្មើសដែលទាន់ជាក់ស្តែង ហើយនាំទៅប្រគល់ឲ្យនាយភ្នាក់ងារក្រុមព្រះនគរបាល (មាត្រា ៤៨២ ក. ព. និងមាត្រា ៥៥ ក. ព. ព.) ។

២.– ក្រៅពីបទឧក្រិដ្ឋ ឬមជ្ឈិមដែលទាន់ជាក់ស្តែង

ក្រៅពីបទឧក្រិដ្ឋ ឬមជ្ឈិមដែលទាន់ជាក់ស្តែង មានតែនាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌តែប៉ុណ្ណោះ ដែលនឹងចាប់មនុស្សបាន ប៉ុន្តែត្រូវឲ្យមានលក្ខខណ្ឌណាមួយក្នុងបណ្តាលក្ខខណ្ឌពីរយ៉ាងដូចតទៅនេះ ៖

ក) មានបង្គាប់ពីតុលាការ ឬ

ខ) បានទទួលបណ្តឹង ។

ក)– នាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ចាប់ ដោយមានបង្គាប់ពីតុលាការ (មាត្រា ២៤៣ ក. ព.)

– ភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ ត្រូវចាប់មនុស្សណាដែលមានដីកានាំខ្លួនឬដីកាចាប់ខ្លួន ដែលតុលាការមុខក្រសួងបេញតំរូវឲ្យចាប់ និងមនុស្សណាដែលមានសាលក្រមកាត់ទោសដាក់គុកធុតរយៈឧទ្ធរណ៍ ។

ដីកានាំខ្លួន ជាសំបុត្រដែលតុលាការមុខក្រសួង (តាមធម្មតា សុភាចារបុរស) ចេញបង្គាប់ឲ្យភ្នាក់ងារកំឡាំងអាជ្ញាទាំងពួងនាំខ្លួនអ្នកត្រូវចោទមកជូនតុលាការនោះ។ ដីកានាំខ្លួននឹងចេញបានតែក្នុងរឿងឧក្រិដ្ឋឬមជ្ឈិមទម្ងន់ ហើយបើអ្នកជាប់ចោទគ្មានទីលំនៅខ្ជាប់ខ្លួនឬបើគួរខ្លាចក្រែងអ្នកត្រូវចោទគេចរត់បាត់ខ្លួន ឬកាលបើអ្នកត្រូវចោទមិនបានចូលទៅសាលាតាមដីកាបង្គាប់ឲ្យចូលខ្លួន (មាត្រា ១៧៥-១៧៤ ក.ព.ព,) ។

ភ្នាក់ងារដែលទទួលសំរេចតាមដីកានាំខ្លួន ត្រូវបង្ហាញដីកានោះទៅអ្នកត្រូវចោទ ហើយប្រគល់ចុងដីកាឲ្យទៅផង (មាត្រា១៧៦ ក.ព ព). ។ រួចត្រូវនាំខ្លួនអ្នកត្រូវចោទទៅជូនតុលាការមុខក្រសួង ដើម្បីសាកសួរក្នុងរយៈវេលា ២៤ ម៉ោង (មាត្រា១៨០ក.ព.ព.)។ ដល់អ្នកត្រូវចោទចូលខ្លួនដល់តុលាការ ដែលបានចេញដីកានាំខ្លួន ហើយដីកានាំខ្លួននោះអស់អំណាចតែប៉ុណ្ណោះ ។ តុលាការនោះនឹងបើកលែងឲ្យនៅក្រៅឃុំក៏បាន, បើកនឹងដាក់ឲ្យឃុំខ្លួនក៏បាន តែត្រូវចេញដីកាមួយទៀត ហៅថាដីកាឃុំខ្លួន (មាត្រា១៨១ក.ព.ព.)។

ដីកាឃាប់ខ្លួន.– បើអ្នកត្រូវចោទគេបបាត់ខ្លួន នោះតុលាការចេញដីកាឲ្យចាប់ខ្លួន ដោយបានសេចក្តីយល់ព្រមជាមុនពីក្រុមអយ្យការ ។ ដីកានេះបើកអំណាចឲ្យភ្នាក់ងារដែលចាប់អ្នកត្រូវចោទនាំខ្លួនត្រង់ទៅគុកតែម្តង ។ (មាត្រា១៨២និង១៨៣ក.ព.ព.)

១)– នាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ចាប់ដោយបានទទួលបណ្តឹង.– អ្នកបេះប្បាប់ខ្លះយល់ថា កាលបានទទួលបណ្តឹងដោយត្រឹមត្រូវ ជាជនណាបានប្រព្រឹត្តបទឧក្រិដ្ឋឬមជ្ឈិម នាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ មានសិទ្ធិចាប់ជននោះមកសាកសួរធ្វើសេចក្តីកត់ហេតុបញ្ជូនទៅព្រះរាជអាជ្ញា ព្រមទាំងជននោះផងឬនឹងបើកលែងជននោះសិន ហើយបញ្ជូនតែពាក្យកត់ហេតុទៅក៏បានដែរ ។ អ្នកដែលយល់ដូច្នេះ អាងដល់មាត្រា ៣៩ក.ព.ព. ដែលមានសេចក្តីដូចតទៅនេះ ៖

«មុខក្រសួងក្រុមព្រះនគរបាលយុត្តិធម៌ត្រូវស៊ើបរកបទល្មើសជាឧក្រិដ្ឋមជ្ឈិមនឹងលហុ ប្រមូលភស្តុតាងនឹងជូនខ្លួនមនុស្សដែលប្រព្រឹត្តបទល្មើសទាំងនោះទៅសាលា ដែលសំរាប់ធ្វើទោសមនុស្សដែលប្រព្រឹត្តបទល្មើសនោះ» ។

តាមយោបល់អ្នកខ្លះទៀត បទបញ្ញត្តិនៃមាត្រានេះមិនជាក់ច្បាស់គ្រប់គ្រាន់ទេ ព្រោះគ្មានមាត្រាឯទៀតមកប្រកបសេចក្តីផងថា នាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌មានសទ្ធិចាប់មនុស្ស កាលគ្រាន់តែបានទទួលបណ្តឹង ។ គេអាចយល់បានថាអ្នកតែងច្បាប់មានបំណងបើកអំណាចឲ្យនាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ចាប់អ្នកប្រព្រឹត្តបទល្មើស បានតែក្នុងរឿងបទល្មើសដែលទាន់ជាក់ស្តែង និងកាលបានទទួលបង្គាប់ពីតុលាការមុខក្រសួង ។

នាម៉ឺននឹងភ្នាក់ងាររាជការដែលពុំមែនជានាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ មានសិទ្ធិចាប់មនុស្សឬទេ ? ត្រង់នេះមានសេចក្តីយល់ផ្សេង ៗ គ្នា ព្រោះគ្មានបទបញ្ញត្តិឯណាសំដែងឲ្យជាក់ច្បាស់ ។

ប្រការ ៤.- នរណាមានអំណាចឃុំឃាំង ? ដើម្បីនឹងឃុំឃាំង ត្រូវធ្វើតាមរបៀបដូចម្តេចខ្លះ ទើបត្រឹមត្រូវតាមច្បាប់ ?

មានតែតុលាការតែប៉ុណ្ណោះ ដែលមានអំណាចឃុំឃាំង ។

ដើម្បីនឹងឃុំឃាំងបាន តុលាការមុខក្រសួងត្រូវចេញសានក្រមកាត់ទោសដាក់គុក ឬចេញដីកាតុលាការ ។ ដីកាតុលាការដែលបើកអំណាចឲ្យឃុំឃាំងបាននោះ គឺដីកាចាប់ខ្លួននឹងដីកាឃុំខ្លួន ។

ដីការចាប់ខ្លួន យើងបានអធិប្បាយរួចមកហើយ

ឯដីកាឃុំខ្លួន គឺជាពាក្យបង្គាប់ឲ្យទទួលខ្លួនអ្នកត្រូវចោទទៅឃុំទុកក្នុងគុក ។ ការចេញដីកាឃុំខ្លួននេះ មិនមែនជាការផ្ដាញ-ផ្ដាល ឬជាការដាក់ទណ្ឌកម្មទេ គឺជាការប្រយ័ត្នកុំឲ្យអ្នកត្រូវចោទគេចខ្លួនបាត់ ឬកុំឲ្យអ្នកជាប់ចោទទៅគុបគិតនឹងសាក្សី ឬបំបាត់ភស្តុតាងបាន ក្នុងពេលដែលស៊ើបសួរ ។

ការឃុំឃាំងដោយមានដីកាតុលាការនេះ ច្បាប់គ្មានកំណត់ថាដល់ពេលយូរប៉ុណ្ណាត្រូវបើកលែងទេ ស្រេចតែលើចៅក្រម ។ តែចៅក្រមអាចដោះឲ្យនៅក្រៅឃុំបាន ។ សំរាប់មនុស្សណាដែលទើបនឹងត្រូវចោទតែមួយដង ហើយដែលគួរត្រូវទោសត្រឹមតែជាបទមជ្ឈិមថ្នាក់ទី ១ នោះច្បាប់ប្រណីឲ្យចាប់មកឃុំបានត្រឹមតែបីថ្ងៃ រួចឲ្យបើកលែងនៅក្រៅឃុំ តែបើបទល្មើសនៃអ្នកត្រូវចោទនោះជាបទមជ្ឈិមដែលទាន់ជាក់ស្ដែង ច្បាប់ក៏មិនប្រណីដូច្នេះដែរ (មាត្រា ១៨៨ ក.ព.ព.) ។

ឯដីកានាំខ្លួន ដែលបានអធិប្បាយរួចមកហើយ នោះមិនមែនបើកអំណាចឲ្យឃុំឃាំងបានទេ គឺគ្រាន់តែឲ្យចាប់ខ្លួនបញ្ជូនទៅតុលាការតែប៉ុណ្ណោះ ។

ប្រការ ៥.– នណារចាប់ឬឃុំឃាំងគេខុសពីច្បាប់ ត្រូវទទួលទោសយ៉ាងណាខ្លះ ?

ជនណាចាប់មនុស្សទៅឃុំឃាំងហើយឃាត់ខន ដោយគ្មានបង្គាប់អំពីរាជការត្រឹមត្រូវតាមច្បាប់ ហើយក្រៅពីបទល្មើសជាឧក្រិដ្ឋ ឬមជ្ឈិមដែលទាន់ជាក់ស្តែង ជននោះត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ២ បើការឃុំឃាំងមិនយូរលើសពី ១០ ថ្ងៃ ។ បើការឃុំឃាំងយូរលើសពី ១០ ថ្ងៃ ត្រូវដាក់ទោសមជ្ឈិមថ្នាក់ទី៣ (មាត្រា ៤៨២ ក.ព.) ។ បើជនដែលឃុំឃាំងគេនោះមិនបើទាំ ឬបង្អត់អាហារ អ្នកជាប់ះប៉ុបែមទៀតផង ត្រូវធ្វើទោសជននោះយ៉ាងធ្ងន់បំផុតតាមថ្នាក់ខាងលើនេះ ឬនឹងធ្វើទោសតាមថ្នាក់ធ្ងន់ទៅទៀតក៏បាន (មាត្រា ៤៨៣ ក.ព.) ។

ជនណាឲ្យគេបាដ្ឋានដោយបេតនា ដើម្បីឲ្យគេឃុំឃាំងមនុស្ស ទោះឥតយកឈ្នួលក្តី ទោះយកឈ្នួលក្តី ជននោះត្រូវទទួលដូចអ្នកឃុំឃាំងគេនោះដែរ (មាត្រា ៤៨៦ ក.ព.) ។

តុលាការណាចេញបង្គាប់ឲ្យឃុំឃាំងមនុស្ស ដែលគ្មានត្រូវចោទជាបទឧក្រិដ្ឋឬមជ្ឈិម ហើយដែលគ្មានត្រូវកាត់ទោសអាជ្ញា

ឬទោសរដ្ឋប្បវេណីបង្ខំដល់រាងកាយទេ តុលាការនោះត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ២ (មាត្រា ២៤៩ ក. ព. ) ។

ក្រៅពីតុលាការមុខក្រសួង បើមន្ត្រីឬអ្នកតំណាងរាជការណាចេញបង្គាប់ឲ្យចាប់មនុស្សទៅឃុំឃាំង មន្ត្រីឬអ្នកតំណាងរាជការនោះត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ២ (មាត្រា ២៤៨ ក. ព. ។

ជនណាជានាយៈកឬជាអ្នករក្សាគេហដ្ឋានសំរាប់ឃុំឃាំង ទទួលមនុស្សយកទៅឃុំឃាំង ដោយឥតដីកាតុលាការ ឬឥតសេចក្ដីស្រង់សាលក្រមដែលតុលាការបានចេញឲ្យ ជននោះត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ២ (មាត្រា ២៥០ ក. ព. ) ។

ជនណាត្រូវគេក្លែងក្លាយប្ដឹងតុលាការជាបទឧក្រិដ្ឋ ឬមជ្ឈិមដោយឥច្ឆាព្យាបាទ កាលតុលាការរកទៅមិនឃើញដូចបណ្ដឹងកាត់សេចក្ដីលែងខ្លួនឬលើកលែងចោទប្រកាន់ ជននោះអាចប្ដឹងយកអ្នកដើមបណ្ដឹងទុច្ចរិតឲ្យត្រូវទោសមជ្ឈិមថ្នាក់ទី ២ បាន (មាត្រា ៥១៤ ក. ព. ) ។

IMPRIMERIE
A. PORTAIL
PHNOM-PENH
TIRAGE 1100 EX.